សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អ
KhmerPost USA
E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

មាតិការរឿង Issue 175 April 26th - May 10th 2015

**Free**

១-ស្វាគមន៍ទិវាកេរ្តិ៍ដំណែលវប្បធម៌....................០២
២-របាយការណ៍អំពីក្លឹប ................................០៤
៣-ខ្មែរដំបូងដែលបានកសាងផ្សារប៉ៃលិន.................០៦
៤-ថ្ងៃទី១៩ ខែឧសភា (ការបោះឆ្នោត)..................០៧
៥-ដំណើរទស្សនកិច្ចលោក អាឡិចស៍ ..................០៨
៦-លោក ហ៊ុន សែន ប្រាប់លោក សម រង្ស៊ី...........១០
៧-ឆ្នាំមមែក្នុងទំនាយមហា................................១២
៨-រមណីដ្ឋានទឹកធ្លាក់ល្បាក់ខោន.........................១៤

**Office:** Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A  Lowell, MA 01852



# សិល្បករជន្ត្រីសម័យ៥០ឆ្នាំមុន រស់ឡើងវិញនៅឡូវែល

## « Don’t think I forgot » Party

ដោយ: ពិន សំខុន

ចុងសប្តាហ៍ទី២៤,២៥មេសានេះឡូវែល ដែលធ្លាប់តែរីករាយនឹងតន្ត្រីនឹងចម្រៀងសម័យមកពីស្រុកខ្មែរ ស្រាប់តែត្រឡប់ទៅរស់នៅក្នុងស្រម័យនៃសម័យ៥០ឆ្នាំមុន ដែល ស៊ិន ស៊ីសាមុត អ្នកចម្រៀងឯក រស់ សេរីសុធា , ប៉ែន រ៉ន អ្នក ចម្រៀងស្រីដ៏ល្បី

តទៅទំព័រទី ០៥

អ្នកចម្រៀងសម័យល្បីល្បាញឆ្នាំ ១៩៦៥ ម៉ុល កាមាច ( Photo Credit: Tory Germann)

## វិចារណកថា

# ទឹករងថ្លាទើបឃើញបាត



ពិន សំខុន

ដោយ: ពិន សំខុន

ស្ថានភាពជាប់គាំងនយោបាយ បានត្រូវបញ្ចប់នៅពេលបង្កើត គ.ជ.ប. ថ្មីមួយរួចមក។ លោក នាយករដ្ឋមន្ត្រី ហ៊ុន សែន ដើរលេងបុណ្យចូលឆ្នាំ សួរសុខទុក្ខញាតិជាមួយលោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិ ជារឿងដ៏មិនដែលប្រទះ ពីមុនមកទេ ដូច្នេះសន្តិភាពដែលទើបនឹងកើត ក្នុងចិត្តពលរដ្ឋនាពេលនេះ បន្ទាប់ពីសង្គ្រាមមិនចេះចប់ជាង២៥ឆ្នាំ រវាងបក្សប្រឆាំងនឹងបក្សកាន់អំណាច តើគួរជឿបានថាឋិតស្ថេរឬទេ? ដូចទឹកកំពុងល្អក់! ដោយប្រទាញប្រទងប្រកបដោយ កម្លាំង ធ្វើឱ្យជាប់គាំងនយោបាយនោះគឺ បន្ទាប់ពីការប្រកាសលទ្ធផលនៃការបោះឆ្នោតសភាជាតិ ខែកក្កដា២០១៣ គណបក្សសង្គ្រោះជាតិ ប្រកែកមិនទទួលយកលទ្ធផល៥៨អាសនៈ ដែលថា **“ជាលទ្ធផលក្លែងក្លាយ”**

តទៅទំព័រទី ០៧






# ស្វាគមន៍ទិវាកេរ្តិ៍ដំណែលវប្បធម៌អាស៊ី

## Welcome to Asian-Pacific American Heritage Month

ដោយៈ ពិន សំខុន

ខែឧសភាបានត្រូវប្រកាសទទួលស្គាល់ដោយសហរដ្ឋអាមេរិកថា ជាខែដែលប្រារព្ធទិវាកេរ្តិ៍ដំណែលនៃវប្បធម៌ជនជាតិអាស៊ាន-ប៉ាស៊ីហ្វិកអាមេរិកាំង។ សារពត៌មានខ្មែរផុសសរអា មានមោទនភាពអនេកកប្បការ នឹងប្តេមរៀបចំទទួលស្វាគមន៍ទិវានេះឱ្យបានប្រសើបំផុត ជាមួយនឹងសហគមន៍ទាំងមូលដែលរស់នៅជុំវិញយើង ពីព្រោះអាមេរិកាបានរីកលូតលាស់សម្បើមប៉ុណ្ណេះ ក៏មានឫសគល់នាំមកពីអាស៊ាន-ប៉ាស៊ីហ្វិក អាមេរិកាំងផងដែរ។ ជនជាតិនៃសាសន៍និមួយៗ នៅពេលមកដល់សហរដ្ឋអាមេរិក បាននាំយកនូវកេរ្តិ៍ដំណែលវប្បធម៌រៀងៗខ្លួន មកប្រណិបត្តិនៅប្រទេសថ្មីនេះ មិនអាចកាត់ផ្តាច់បានឡើយ ទង្វើនេះមិនត្រឹមតែម្ចាស់ស្រុកគេមិនហាមប្រាមតែប៉ុណ្ណោះទេ ថែមទាំងលើកដំកើងថែមទៀតមិនដូចកាលពីយើងនៅស្រុកនោះទេ ហេតុនេះហើយបានជានៅតំបន់ឡូវែល ឬនៅឡុងប៊ីច ឬហ្វិឡាដែលភ្យានៅវ៉ាស៊ីនតោន ដំបន់ដែលមានខ្មែររស់នៅច្រើនសហគមន៍ខ្មែរយើង អាចថែរក្សាងើបមុខបង្ហាញភាពសង្ហារនៃ ភ្លេង ចម្រៀង របាំ បង្ហាញពីសម្លៀកបំពាក់ បង្ហាញពីក្រុងខ្មែរ បង្ហាញពីអក្សរខ្មែរបង្ហាញភោជនីយដ្ឋានខ្មែរ ស្នើមុខនឹង សាសន៍ដ៏ទៃឯទៀត ដែលមកចាក់ឫសមុនយើង នៅទឹកដីសហរដ្ឋនេះដែរ។

នៅលើដែនដីនៃប្រជាជនអន្តោប្រវេសន៍ ការថែររក្សាកេរ្តិ៍វប្បធម៌ខ្មែរ មានសារសំខាន់ខ្លាំងណាស់ ក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស គ្រួសារនឹងសហគមន៍បើគេមិនខិតខំថែរទាំវាទេ មិនច្បាស់ជាវប្បធម៌នោះរស់បានទេ។ គេអាចនៅចងចាំបានកាលពីជាង២០ឆ្នាំមុន សហគមន៍និមួយៗ ទាំងស្បែកស ទាំងខ្មៅ ទាំងលឿង ពុំមានការលើកដំកើងវប្បធម៌ជាតិខឡួន ដូចពេលនេះទេ ដែលជាហេតុធ្វើឱ្យដាច់ចំណងគ្រួសារ កូនចៅគ្មានការអប់រំពីឪពុកម្តាយ ដោយរនាំងភាសា រនាំងវប្បធម៌ នាំឱ្យស្រា ស្រី ល្បែង គ្រឿងញៀន ចូលមកជំនួសការធាត់ធំនៃកូនចៅ លទ្ធផលកើតហ្គេងមនុស្សជរាមុនអាយុ ភាពក្រីក្រនៅជាប្រចាំពន្ធនាគារពេញប៉ោង ទីបូជាខ្មោចលែងប្រើសម្រាប់តែមនុស្សចាស់ទេ អ្នករៀនសូត្របានខ្ពស់ក៏មិនសូវសម្បូរ។ លក្ខណខុសគ្នានៃក្រុមប្រជុំកោះអាស៊ីប៉ាស៊ីហ្វិក គឺប្រទេសទាំងមូល បានក្លាយជាអាមេរិកាំង ប្រើច្បាប់ដែលជាសីលធម៌អាមេរិកាំងរីឯជនជាតិអាស៊ីផ្សេងទៀត គឺគ្រួសារបានប្តូរប្រទេសមក រស់នៅសហរដ្ឋអាមេរិក តែបញ្ហារក្សាវប្បធម៌ដើមកំណើត ត្រូវបានរក្សាទុក។

តែអីឡូវនេះ ចរន្តបានប្តូរទិសហើយ គ្រួសារខ្មែរនឹងអាស៊ីទាំងអស់ រីករាយនឹងឃើញកូនចៅសម្តែងសិល្ប របស់ជាតិខ្លួន ស្លៀកសំពត់ ខោពាក់អាវប្រពៃណី នេះជាការខិតចូលមកជិតគ្នារវាងម្តាយឪពុកនឹងកូនចៅ ដោយក្តីស្រឡាញ់មេត្តា ជាកត្តាដែលអ្នកវិទ្យាសាស្ត្រកំណត់ថាគ្រួសារជនជាតិអាស៊ីយើងជាច្រើន បានត្រឡប់មករកផ្លូវត្រូវឃើញហើយ។

កាលពីឆ្នាំមុន **ខ្មែរផុស ស.រ.អា** បានអញ្ជើញភ្ញៀវកិត្តិយសមួយរូបមកពីតិចសាស់ ឈ្មោះស៊ីចាន់ ស៊ីវ មកបង្ហាញជាគំរូដល់សហគមន៍ យើងថា ដោយសារការខិតខំប្រឹងប្រែង ប្រកបដោយសុច្ចរិត ខ្មែរសាមញ្ញម្នាក់ ក៏អាចឡើងដល់ឋានកំពូល ជាឯកអគ្គរដ្ឋទូត ស.រ.អា ប្រចាំអង្គការសហប្រជាជាតិបានដែរ។ នៅថ្ងៃទី៨ខែឱសភាខាងមុខ យើងនឹងណែនាំសហគមន៍យើង ឱ្យជួបស្គាល់មនុស្សម្នាក់ទៀត គឺចៅក្រមនៃតុលាការកំពូល អាមេរិកាំង នៅរដ្ឋ ជចជ្យា គឺលោក លិមម៉េងជាខ្មែរម្នាក់ទៀត ធ្លាប់ឆ្លងកាត់ប្រវត្តិខ្លោចផ្សារ ដូចអ្នកឯទៀតដែរ ប៉ុន្តែការតស៊ូប្តូរផ្តាច់ក្នុងជីវិត ប្រកបដោយភាពក្លាហាន នៅតែផ្តល់រង្វាន់ខ្ពង់ខ្ពស់ មិនដែលមានពីមុនមកបានដែរ។

នៅឡូវែលរដ្ឋម៉ាសាឈូសិត ក៏មានមនុស្សគំរូ ចូលក្នុងប្រវត្តិសាស្ត្រខ្មែរនៅសហរដ្ឋនេះដែរ ដូចជាលោក អ៊ុំង រិទ្ធីបានជាប់ជាសមាជិកក្រុមប្រឹក្សាសាលាក្រុងខ្មែរដំបូងបង្អស់បាន២អណត្តិនៅលីន នៃរដ្ឋដដែល មានលោក ហុង ណេតដែលកំពុងធ្វើការជាសមាជិកសភាខ្មែរទី១ នាអណត្តទី២ នៅទីក្រុងលីន ក៏មានឈ្មោះចូលបញ្ជីប្រវត្តិសាស្ត្រដែរ ចុងក្រោយបង្អស់ មានលោក រ៉ាឌី ម៉ម ក៏បានជាប់ឆ្នោត ជាតំណាងរដ្ឋសង្កាត់លេខ១៨ខ្មែរទីមួយ នៅក្នុងរដ្ឋបាលអាមេរិកាំងទៀត។ នៅមានមនុស្សកិត្តិយសមួយចំនួនទៀតដែលបានទទួលការតែងតាំងក្នុងឋានខ្ពស់មិនដែលមានពីមុនមកដែរ ដូចជា លោក ដានីញែល ពៅជានាយកសាលាខ្មែរទី១ នៅហ្វិឡាដែលហ្សៀនាងបូរ៉ា ជាមរូន បានទទួលការតែងតាំងជានាយកប្រតិបត្តគណកម្មការអេស៊ានរដ្ឋម៉ាសាឈូសែត ។ល។ នេះជាសញ្ញាថ្មីនៃការ ដែលមនុស្សមកពីប្រទេសអាស៊ីកាន់តែច្រើន ចេញមកបំពេញតួនាទីកិត្តិយស ក្នុងស្មារតីបរិសុទ្ធ ដោយចំណេះ នឹងដោយព្យាយាម ពីព្រោះតែការលើកដំកើង ដោយទិវាកេរ្តិ៍ដំណែលវប្បធម៌អាស៊ាន-ប៉ាស៊ីហ្វិកនេះ។

នៅលើទឹកដីពហុវប្បធម៌អាមេរិកាខាងជើង ជនជាតិអាស៊ី រាប់ទាំងខ្មែរផង កំពុងរៀបដំណើរផ្លូវថ្មីរបស់ខ្លួន ស៊ុចង្វាក់យ៉ាងខ្លាំង ទៅនឹងដំណើរអភិវឌ្ឍន៍សហរដ្ឋអាមេរិក មនុស្សសំខាន់ៗឆ្លៀតពេលមកឱ្យគំរូ នឹងណែនាំអ្នកជំនាន់ក្រោយ មាតាបិតានឹងកូនចៅខិតចូលជិតគ្នាដោយក្តីស្រឡាញ់ ជីវភាពនឹងសុខភាពក៏បានទទួលការគាំទ្រដល់ជីវិតបានប្រសើរជាងមុន ដែលទាំងនេះធានាដល់អនាគតគ្រួសារ បានច្រើនហើយ តែនៅមានចំណុចនឹងស្មារតីអវិជ្ជមានក្នុងវប្បធម៌ខ្លះទៀតនៅឡើយ ដែលតម្រូវឱ្យយើងពួតដៃជម្រះចេញឱ្យបានក្នុងអនាគត៕



# ពិធីបុណ្យចូលឆ្នាំខ្មែរនៅក្រុងឡូវែល



ដោយៈ ស្តាយ បុណ្យ

ទីក្រុងឡូវែល រដ្ឋម៉ាស្សាឈូសេតៈ តាមទំនៀមទម្លាប់ខ្មែររដូវបុណ្យចូលឆ្នាំខ្មែរ គឺជាវេលាដ៏មនោរម្យសម្រាប់ការជួបជុំបងប្អូន និងក្រុមគ្រួសារមកពីទីជិតឆ្ងាយ ដើម្បីទទួលទានអាហារឆ្ងាញ់ៗជុំគ្នា និងលេងល្បែងប្រជាប្រិយ និងទៅវត្តយកចង្ហាន់ប្រគេនព្រះសង្ឃ ដើម្បីធ្វើបុណ្យ ចែកទាន និងឧទ្ទិសកុសលដល់អ្នកដែលបានចែកឋាន។

ពិធីចូលឆ្នាំខ្មែរ ប្រារព្ធឡើងដើម្បីអបអរឆ្នាំថ្មី និងថែរក្សាប្រពៃណី វប្បធមិពីដូនតា។ ការលេងល្បែងប្រជាប្រិយខ្មែរ ដូចជាចោលឈូង បោះអង្គុញ លាក់កន្សែង ទាញព្រ័ត្រ និងរាំវង់ស្គរដីជាដើម គឺជាសុទ្ធតែនាំមកនូវភាពមនោរម្យ និងសាមគ្គីភាពខ្មែរ។

ឆ្នាំនេះអ្នកក្រុងឡូវែល រៀបចំពិធីបុណ្យឆ្នាំ ខ្មែរស្ទើរពេញ១

**តទៅទំព័រទី ២៧**

# REMEDIUM PHARMACY

2 VINAL Square
N. Chelmsford, MA 01863

Phone: (978) 251-7070



## FREE Daily Home Delivery

Blisterpack Packaging

Friendly Consultations

Compounded Medications

Easy Transfers

បុគ្គលិកទាំងអស់របស់ឱសថស្ថានរីមីឌីមយើងខ្ញុំមានបទពិសោធន៍គ្រប់គ្រាន់ក្នុងការបំរើសេវាផ្តល់ឱសថជូនដល់សហគមន៍ខ្មែរ។ គេទាំងអស់គ្នាបានត្រៀមរួចជាស្រេចដើម្បីជួយ និង ត្រៀមបំរុងជានិច្ច ដើម្បីប្រើគ្រប់ជំនាញ និងការពិសោធន៍ក្នុងការបំរើលោកអ្នក។




ឱសថស្ថានរីមីឌីម ផ្តល់ជូនលោកអ្នកនូវ:

**ជូនឱសថឲ្យដល់លំនៅស្ថានដោយឥតគិតថ្លៃ**
**ដាក់ឱសថក្នុងបន្ទះបែងចែកឱសថសំរាប់ប្រើតាមពេល**
**ការពិគ្រោះយោបល់យ៉ាងរាក់ទាក់ស្និទស្នាល**
**មានផ្តល់ជូនម្សៅថ្នាំលាយ**
**ភាពងាយស្រួលក្នុងការផ្ទេរចេញចូល**



Cristina គ្រីស្ទីណា:
គ្រីស្ទីណាមានការពិសោធន៍គ្រប់គ្រាន់នៅក្នុងកិច្ចការបំរើសហគមន៍ខ្មែរក្រុងឡូវែលអស់រយៈពេលជាង៣ឆ្នាំមកហើយ។អ្នកស្រីគឺជាឱសថការិនីដែលគ្រប់គ្រងឱសថស្ថាន រីមីឌីម នេះ ហើយគាត់ក៏អាចធ្វើការពិគ្រោះអំពីឱសថ ជូនលោកអ្នកដល់ផ្ទះផងដែរ។ ដោយសារការផ្តល់នូវសេវាកម្មផ្នែកឱសថនេះ បានច្បាស់លាស់ទើប អ្នកស្រីអាចបង្កើត បាននូវចំណងមិត្តភាពយ៉ាងល្អប្រពៃក្នុងសហគមន៍ខ្មែរក្នុងក្រុងឡូវែល ហើយអ្នកស្រីមានសេចក្តីរីករាយណាស់ដើម្បីរង់ចាំបំពេញនូវបំណងរបស់លោកអ្នកដែលត្រូវការឱសថ។



Pahim លោកប៉ាហ៊ីម:
គឺជាបុគ្គលម្នាក់ដែលមានការគោរពច្រើននៅក្នុងសហគមន៍ខ្មែរ គាត់ក៏ជាសមាជិកម្នាក់នៅក្នុងគណកម្មការវត្តត្រៃរតនារាម ហើយធ្លាប់មានការពិសោធន៍ជាច្រើនឆ្នាំក្នុងការជួយសហគមន៍ដែលត្រូវការព្យាបាលជម្ងឺ។ ក្នុងរយៈកាលកន្លងមក គាត់ធ្លាប់បានធ្វើការយ៉ាងច្រើនជួយគាំទ្រដល់អ្នកជម្ងឺនៅមជ្ឈមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែលនិងមណ្ឌលសុខភាពពេទ្យមេត្តាព្រមទាំងធ្លាប់បានចូលរួមចំណែកក្នុងការថែទាំដោយឱសថសំរាប់សហគមន៍ខ្មែរក្រុងឡូវែលអស់រយៈពេលជាង២ឆ្នាំផងដែរ។ ក្នុងនាមជាសមាជិកម្នាក់នៃឱសថស្ថានរីមីឌីម គាត់នឹងបន្តធ្វើការបំរើឲ្យកាន់តែខ្លាំងឡាថែមទៀតដើម្បីបំពេញនូវតំរូវការក្នុងការផ្តល់ឱសថដល់លោកអ្នក។



Dary ដារី:
តែងបានយកចិត្តទុកដាក់ជាប់ជានិច្ចក្នុងសេវាកម្មផ្តល់ឱសថ ដើម្បីបំពេញតាមតំរូវការនៃសហគមន៍ខ្មែរក្រុងឡូវែលអស់រយៈជាង២ឆ្នាំមកហើយ ហើយតែងទទួលបាននូវការកោតសរសើរពីសំណាក់អតិថិជនដែលបានជួបប្រាស្រ័យជាមួយគាត់។ ក្នុងឋានៈជាអ្នកបច្ចេកទេសម្នាក់របស់ឱសថស្ថាន គាត់មានការយល់ដឹងយ៉ាងជ្រៅជ្រះអំពី តំរូវការ និងប៉ិនប្រសប់ក្នុងការផ្តល់សេវាជូនលោកអ្នកនិងចេះសំដែងនូវការគោរពយ៉ាងទន់ភ្លន់ចំពោះលោកអ្នកផងដែរ។



Kelly ខែលលី:
គឺជាឱសថការិនីយើងដែលអាចនិយាយភាសាខ្មែរហើយដែលយកចិត្តទុកដាក់ចេះជួយលោកអ្នក។ គាត់ជាឱសថការិនី ចេញពីមហាវិទ្យាល័យឱសថសាស្ត្ររដ្ឋម៉ាសាឈូសេត និង ពេញចិត្តធ្វើការបំរើសហគមន៍ខ្មែរដែលគាត់គឺជាសមាជិកម្នាក់នៃសហគមន៍នេះដែរ។



Daniela ដានីញែលឡា:
មានជំនាញច្បាស់លាស់ក្នុងការវេចខ្ចប់ឱសថដាក់ក្នុងបន្ទះពង្រាយថ្នាំសំរាប់ប្រើតាមពេល ហើយធ្លាប់ឆ្លងកាត់ការថែទាំអ្នកជម្ងឺខ្មែរដែលរស់នៅក្នុងក្រុងឡូវែលនេះអស់រយៈពេលជាង៣ឆ្នាំមកហើយ។ ប្រសិនបើលោកពេញចិត្តនឹងការប្រើថ្នាំដាក់ក្នុងបន្ទះបែបនេះ ដានីញែលឡាពេញចិត្តណាស់នឹងធ្វើកិច្ចការនេះជូនលោកអ្នក។



Kassandra កាសាន់ដ្រា:
គឺជាបុគ្គលិកដែលមានការពិសោធន៍ច្រើនក្នុងការធ្វើទំនាក់ទំនងជាមួយសហគមន៍ខ្មែរ និងស្បានិសសដែលរស់កក្នុងក្រុងឡូវែលនេះ។
លោកអ្នកអាចនឹងពេញចិត្តអំពីភាពរាក់ទាក់រាល់ពេលនិយាយឆ្លើយឆ្លងតាមទូរស័ព្ទជាមួយនាង និងប៉ិនប្រសប់ក្នុងការរៀបចំឱសថជូនលោកអ្នកនៅរាល់ពេលដែលលោកអ្នកត្រូវការ។

# របាយការណ៍អំពីក្លឹបសារព័ត៌មាន ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៥

ដោយៈ វិឆាត ហារ ជូនៀ

ប្រែសម្រួលដោយៈ មួង ណារ៉េត

កាលពីថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៥ កម្មវិធីរបស់ក្លឹបសារព័ត៌មានខ្មែរផុស បានចាប់ផ្តើមដោយដាក់បញ្ចាំងខ្សែវីដេអូខ្លីមួយ អំពីចំណាប់អារម្មណ៍របស់អ្នកក្រុងឡូវែល ពាក់ព័ន្ធនឹងសំណើសាងសង់បូជនីយស្ថានមួយសម្រាប់សហគមន៍ខ្មែរ នៅក្នុងបរិវេណសាលាក្រុងឡូវែល។ លោក ចែក ស៊ីលវ៉ា ដែលតំណាងឱ្យមជ្ឈមណ្ឌលសុខភាព និងជីវិតនៃទីក្រុងឡូវែល មានប្រសាសន៍ថា គាត់ពិតជាគាំទ្រឱ្យមានការសាងសង់បូជនីយស្ថាននេះ។ លោក សាកូ ដែលតំណាងឱ្យសមាគមខ្មែរ (CMAA) មានប្រសាសន៍ថា លោកចង់ស្នើឱ្យគេសាងសង់រូបអង្គរវត្ត ដើម្បីជានិមិត្តរូបតំណាងឱ្យសហគមន៍ខ្មែរយើង។ លោក សុវណ្ណា ដែលតំណាងឱ្យសមាគមខ្មែរ(CMAA)ដែរ បានលើកឡើងថា គម្រោងសាងសង់បូជនីយស្ថាននេះ មានសារសំខាន់ខ្លាំងណាស់ ដ្បិតសហគមន៍ដទៃទៀតនៅក្រុងឡូវែល ក៏គេមានសង់បូជនីយស្ថានបែបនេះរួចហើយដែរ។ លោក សុវណ្ណា បានបន្ថែមថា "បូជនីយស្ថានដែលនឹងត្រូវសាងសង់នេះ គប្បីជារបស់មួយដែលប្រជាពលរដ្ឋនៅក្នុងសហគមន៍គ្រប់គ្នា ចាត់ទុកថាជាទីគាប់ប្រសើរ តំណាងឱ្យមោទនភាពជាតិខ្មែរយើង"។ អ្នកនៅហាងអមរាបូទិកបានលើកឡើងថា "ការផ្តួចផ្តើមសាងសង់បូជនីយដ្ឋាន គឺជាការល្អ ដែលនឹងអាចជួយផ្សះផ្សាសហគមន៍ខ្មែរយើងបាន"។ លោក រ៉ាឌី ម៉ុម



លោក រ៉ាឌី ម៉ុម ដែលជាតំណាងរាស្ត្រជាប់ឆ្នោត

ដែលជាតំណាងរាស្ត្រជាប់ឆ្នោត បានពន្យល់ថា គម្រោងសាងសង់បូជនីយស្ថានតាមរចនាបទខ្មែរនេះគឺផ្តួចផ្តើមឡើង ដោយលោកអភិបាលក្រុងឡូវែល រ៉ត់នី អ៊ីលៀត។ លោក រ៉ាឌី ត្រូវបានលោកអភិបាល ក្រុងចាត់តាំងឱ្យចូលរួមក្នុងគណៈកម្មាធិការរចនារូបបូជនីយស្ថាន។ លោកមានប្រសាសន៍ថា "ក្រុងឡូវែលជាភូមិឋានរបស់យើង។ យើងមាន របររកទទួលទាននៅទីនេះ។ យើងទៅរៀនក៏នៅទីនេះ។ យើងរស់នៅទីនេះ" ម្ល៉ោះហើយបូជនីយស្ថានមួយនេះ "នឹងជួយផ្សារភ្ជាប់ទំនាក់ទំនងរបស់ យើងទៅនឹងសហគមន៍ដទៃទៀតនៅក្នុងទីក្រុងឡូវែលទាំងមូល"។ គម្រោងនេះ នឹងសរបញ្ជាក់ឱ្យឃើញថា ទីក្រុងឡូវែល ពិតជាទទួលស្វាគមន៍សហគមន៍ខ្មែរយើងទាំងពេលអតីតកាលបច្ចុប្បន្នកាល និងអនាគតកាល។ លោក រ៉ាឌី បានបន្ត ពន្យល់ទៀតថា គណៈកម្មាធិការរបស់អភិបាលក្រុង នឹងជ្រើសរើសគំរូបូជនីយដ្ឋានចំនួនបី ដើម្បីឱ្យបងប្អូននៅក្នុងសហគមន៍ខ្មែរបោះឆ្នោតជ្រើសយករចនាបទចុងក្រោយមួយ។



សុបិន្ត និង សំ ខុន ភិន អ្នករៀបចំកម្មវិធី



លោកបណ្ឌិត គង់ សេងលី

លោកបណ្ឌិត គង់ សេងលី ដែលជាប្រធានអង្គការក្រុងខ្មែរ (Cambodia Town) ត្រូវបានអញ្ជើញឱ្យ មានប្រសាសន៍ អំពីគម្រោងបូជនីយស្ថានមួយដាច់ដោយឡែកទៀត ដែលកំពុងស្ថិត ក្នុងការពិចារណា និងត្រូវសាងសង់នៅក្នុងតំបន់សហគមន៍ខ្មែរ។ គាត់បានពន្យល់ថា មានគេបរិច្ចាគដីច្រមុះជ្រូក ដែលស្ថិតនៅផ្លូវកែងរវាង ផ្លូវ Branch StreetnigMiddlesex Street ដើម្បីសាងសង់បូជនីយស្ថាននេះ។ រចនាបទនៃបូជនីយស្ថានរបស់គម្រោងក្រុងខ្មែរនេះ ត្រូវបានជ្រើសរើសរួចហើយ។ បូជនីយស្ថាននេះ គឺជារូបព្រហ្មបាយ័នមុខបួន ដែលមានកម្ពស់ ៨ ហ្វីត។ សព្វថ្ងៃនេះ ជាងចម្លាក់កំពុងឆ្លាក់រូបបូជនីយ ស្ថាននេះនៅឯស្រុកខ្មែរ។ ពេលធ្វើរួច គេនឹងដឹកមកក្រុង



លោក អាដាម ព្រិល

ឡូវែល។ ថវិកាទាំងអស់សម្រាប់គម្រោងបូជនីយស្ថានព្រហ្មមុខបួននេះ គឺបានមក ពីក្រសួង វប្បធមិ នៅប្រទេសកម្ពុជា។

លោក អាដាម ព្រិល

**តទៅទំព័រទី ២០**



# KhmerPost USA - April 9, 2015 Press Club Notes

The April 9, 2015 PC began with a video in which some residents of Lowell shared their thoughts on the proposal to erect a Cambodian community monument at Lowell City Hall. Jack Silva of Lowell Health and Lifestyle Center said it would be great to have such a monument. Sako of SMAA said that Angkor Wat would be a great symbol for the community. Sovanna, also of CMAA, said it was a great project because most of the other communities in Lowell already have similar monuments. He added that the monument "should be something very prideful for everyone in the community." Someone at Amara Boutique said the monument was "an excellent idea that will help heal the community."

State Representative Rady Mom explained that the current effort to place a Cambodian monument at City Hall started with a motion by Mayor Rodney Elliott. Representative Mom, who was appointed to the monument design selection committee by the mayor, said "Lowell is our home, we have businesses here; we go to school here; we live here" and that a monument like this will "help tie us in to the rest of the city." It will show that the city of Lowell welcomes the Cambodian community, past, present and future. Representative Mom also explained that the mayor's committee will select three monument designs from all submitted and then the entire community will vote to select the final design.

Dr. Sengly Kong, who is the president of the Cambodia Town organization, was then asked to speak about another monument that is being considered for that neighborhood. He explained that a triangle of land at the intersection of Branch Street and Middlesex Street has been donated for a location of this monument. The design has already been selected: it is a four-faced Bayon Monument that will be eight feet tall. It is being carved in Cambodia right now and will be shipped to Lowell when it is complete. The funding for the statue has been donated by the Cambodian Ministry of Culture.

Adam Pril, the leader of the Cupples Square Merchants Association, said he "agreed to disagree" about the Cambodia Town monument. He supports Cambodian unity but asked whether all the Cambodian people in Lowell supported this monument. He also question whether it was appropriate to use money supplied by the current Cambodian government to build a monument in Lowell.

Sidney Liang, who is also a member of the Mayor's Cambodian Monument Committee, said there is a lot of friction in Lowell because of politics in Cambodia today. He suggested it would have been better for the Cambodian government to use the money to help the poor people of Cambodia rather than to pay for a monument in Lowell. He thinks a monument would be more valued by the people of Lowell if they paid for it themselves. Whatever monument is installed in Lowell, he wants it to be a unifying symbol. He is glad that there will be a Cambodian monument at City Hall. The most recent ethnic monument, the one erected by the Armenian community, cost $65,000. He predicts the Cambodian monument will cost at least that much.

Kevin Coughlin, the Deputy Director of the city's Planning and Development Office, said the government of the city of Lowell sees the Cambodian monument as an important symbol and a unifying force. There are many people on the selection committee including artists and representatives of organizations in the Lowell Cambodian community. He also hopes that the creation of the Cambodian monument will be part of a bigger effort by city government to create a "monument garden" on the grounds of City Hall. This will be a peaceful, natural place where people will be able to relax and contemplate all of the monuments in the middle of the busy city of Lowell.

## តមកពីទំព័រទី ០១ សិល្បករតន្ត្រីសម័យ៥០ឆ្នាំមុនរស់ឡើង...

ឈ្មោះ ហើយក៏មានក្រុមអ្នក ចម្រៀងវ័យក្មេងនៃសម័យនោះ ចេញមកព្រោង ព្រាត កំដ៏ការចងចាំ ដ៏គួរឱ្យរំភើបរបស់ខ្មែរជំនាន់ឆ្នាំ១៩៦០ដែរ នេះដោយសារការមកដល់ឡូវែល នូវការបញ្ចាំងខ្សែភាពយន្តឯកសារ «**កុំស្មានបងភ្លេច**»(Don’t Think I forgot)១សប្តាហ៍របស់ជន ផុឡូស៊ី (John Polozzi ) នឹងក្រុមតន្ត្រីករទៅក្នុងសូបិន នៃឆ្នាំ៦០ដ៏រីករាយនៃកម្ពុជាដោយសិល្បករនៅតែមានទឹកដមនៃថ្វីដៃដូរតន្ត្រីខ្ពស់នៅឡើយ ។ លោក ហុង សំឡី ៦៨ នៅ សំដែងនៅឡើយ រស់នៅប្រទេសបារាំង នឹង យូរ៉ុប ជាអតីតអ្នកកាន់គីតាក្រុម «**បាយ៉ន, អប្សរា, បក្សីចាំក្រុង**» , លោក មុល កាម៉ាច ៧៣ ចូល និវត្តន៍នៅបារាំង តែប្រឹងហាត់ឡើងវិញក្នុងគម្រោងមកសម្តែងនៅអ្នកចម្រៀងជើងចាស់ម្នាក់ទៀតឈ្មោះ តូ ច្រៀង តំណាងឱ្យអ្នកចម្រៀងបែប«**រ៉ាប់**»ជំនាន់នោះ គឺ អ៊ុំ ឡារ៉ាំង ដែលជាម្ចាស់បទ «**ជិះស៊ីក្លូ**», នៅមានសិល្បករវ័យក្មេង២រូបទៀតគឺ ស៊ិន សេដាកុល ជាចៅបង្កើតរបស់ លោក ស៊ិន ស៊ីសាមុត ៣៣ ទើបផ្តើមសម្តែង ១០ឆ្នាំចុងក្រោយនេះសោះតែទឹកដមនៃសម្លេង ដែលច្រៀងបទជីតាខ្លួន អាចនឹងធ្វើឱ្យលោក តា ពេញចិត្តជាមិនខាន សព្វថ្ងៃជាប្រធាននៃមូលនិធិ ស៊ិន ស៊ីសាមុត នៅកម្ពុជា, មករបស់សិល្បករចាស់ៗខ្មែរបាត់បង់យ៉ាងគួរឱ្យស្តាយ ស្រាប់តែអ្នកទាំងនោះមួយចំនួន បានលេចធ្លោឡើងមកវិញ ដូចមុនដដែលគួរឱ្យរំភើបពន់ពេកណាស់ ។

មុននឹងថតរូមបញ្ចប់ជាអនុស្សាវរីយ៍ ស៊ិន សេដ្ឋាកុល នឹង ឆោម និមល បានច្រៀងចម្រៀងមួយបទទៀត របស់ ស៊ិន ស៊ីសាមុត ដែលមានឈ្មោះថា«**កុំស្មានបងភ្លេច**» បានធ្វើឱ្យរាត្រីសូបិននៃសាធារណជនជាភ្ញៀវ នឹងជាអ្នកសំដែងផង







តំណាងរដ្ឋ រ៉ាដី ម៉ម និងអភិបាលក្រុងរដ្ឋរ៉តនី អេឡីយ៉ុត ថ្លែងអំណរគុណ



ឯករបស់យុវជនឆ្នាំ៦០ចំនួន៦នាក់ មកសម្តែងនៅសាលសំពៅមាស ។ ភ្ញៀវប្រមាណ៥០០រយនាក់ បានមកចូលរួមការប្រគុំតន្ត្រី «រ៉ក» នៃសិល្បករមានវ័យពី៦០ទៅ៧០ឆ្នាំ ប្រមូលប្រមាន១០ឆ្នាំពីគ្រប់តំបន់នៃពិភពលោក ។ភ្ញៀវភាគច្រើនជាអាមេរិកាំងស ជាកូនកាត់ ជាខ្មែរទាំងចាស់ក្មេង ជិតពាក់កណ្តាល ហើយភាគច្រើននៃភ្ញៀវទាំងនោះ បានមើលកុនឯកសារនោះរួចហើយ ។

ដូចត្រូវមន្តអាគម ភ្ញៀវទាំងអស់ បានលុងអាមេរិក ម្ចាស់បទដ៏ល្បីល្បាញ «**បងរង់ចាំចន្ទ, កូនសូមលាអ្នកម្តាយ,អូនយំរឿងអ្វី**», លោក មុល កាញុល ៧០ បងប្អូនបង្កើត ជាមួយកាម៉ាចបែកគ្នា៤០ឆ្នាំមកហើយ ជាអ្នក កាន់គីតា នឹងតែងបទចម្រៀង រស់នៅសហរដ្ឋអាមេរិក ទើបចាប់ហាត់ឡើងវិញប្រមាណ៤,៥ឆ្នាំ ចុងក្រោយ, លោកទូច សៀងតាណា ៥៨ ធ្វើការ នៅក្រសួងគណរដ្ឋមន្ត្រីខ្មែរទើបហាត់ឡើងវិញជាអតីតក្រុម«**ដ្រាកា**»ជាអ្នកតែងបទ អ្នកកាន់គីតា អ្នកច្រៀង, នៅមាននាង ឆោម និមល ជាអ្នកចម្រៀងវ័យក្មេង កំពុងល្បីឈ្មោះ ច្រៀង តំណាងឱ្យតារាឯកចម្រៀងស្រីបាត់ខ្លួនទៅហើយ គឺ នាង រស់ សេរីសុធា នាង ប៉ែង រ៉ន, រូមដំណើរ មានអ្នកវាយស្គ ងិន សំសីហា អ្នកលេងឧបករណ៏ (អ៊ក)នឹងគីតា ទាំង៣នាក់សុទ្ធតែមកពីកម្ពុជា ។

ក្លឹងផ្សែងនៃមន្តអាគមអតីតកាលឆ្នាំ៦០,៧៥ កើតឡើងបន្ទាប់ពីទស្សនាខ្សែភាពយន្តដែលរៀបរាប់ពីប្រវត្តិសាស្រ្ត ដែលមិនដែលចងក្រងពីមុន



នោះ ស្ទើរបញ្ចប់មិនបាន ៕



# ខ្មែរដំបូងគេដែលបានកសាងផ្សារប៉ៃលិននៅឡូវែល

ដោយៈ សូបិន ពិន

លោក ឡាច ប៊ុនរិទ្ធ អតីតនាយទាហ៊ានបញ្ជូនសារ នឹងភរិយា ម៉ាលិ ថៃ ជាម្ចាស់នៃភោជនីយដ្ឋានប៉ៃលិន បានផ្តល់កិច្ចសម្ភាសន៏ដល់សូបិន កាលពីថ្ងៃទី១៦មេសា២០១៥ នៅភោជនីយដ្ឋានរបស់លោក ស្តីអំពីកំណើតនៃពាណិជ្ជកម្មនៃសហគមន៏ខ្មែរ ដែលបានក្លាយទៅជាក្រុងខ្មែរនាពាឆ្នាំចុងក្រោយនេះ មានអត្ថន័យដូចតទៅ

**ខ្មែរផុសៈ** ជំរាបសួរ លោក ប៊ុនរិទ្ធ ឡាច ជំរាបសួរលោកស្រី មាលី ថៃ ខ្ញុំមកនេះដើម្បីស្វែងយល់ដឹងអំពីប្រវត្តិ នៃតំបន់ពាណិជ្ជកម្មខ្មែរនៅឡូវែលនេះដោយសារ លោកនឹងលោកស្រីជាចាស់ទុំនៃតំបន់ផង នឹង ដោយសារតែជាម្ចាស់នៃភោជនីយដ្ឋានប៉ៃលិន ដែលបានធ្វើឱ្យតំបន់ទាំងមូលមានឈ្មោះថាប៉ៃលិនទៀតផង□ តើលោកលោកស្រី មកដល់ឡូវែល នេះពីពេលណាមក? ហើយពេលនោះតំបន់ប៉ៃលិននេះ មានភិនភាគយ៉ាងណា? ហើយមានការវិវត្តន៏ យ៉ាងដូចម្តេចដែរ?

**ឡាច ប៊ុនរិទ្ធៈ** ឡាចបាទជម្រាបសួរ! ខ្ញុំមកដល់តំបន់នេះនៅឆ្នាំ១៩៨១ ទៅរៀននៅវិទ្យាល័យបូស្តុន Boston រហូតដល់ជាប់បានអេគីវ៉ាឡង់ Equivalence បន្ទាប់មកទៅរៀន ២ឆ្នាំ ទៅមកខាងអេឡិកត្រូនិក ឌីជីថលរៀនចប់នៅឆ្នាំ១៩៨៥ ក៏មកឡូវែលយើងនេះ ទៅធ្វើការនៅ វ៉ាំង Vang



អ្នកទី១? អ្នកស្រី មាលី ថៃ អ្នកទី២ អ្នកស្រី សុបិន្ត ភិន អ្នកទី៣ លោក ឡាច ប៊ុនរិទ្ធ

**ខ្មែរផុសៈ** ខ្ញុំធ្លាប់ឮថា វ៉ាំង ជារោងចក្រធំណាស់ មានមនុស្សធ្វើការ១ម៉ឺននាក់ សម្រាប់ធ្វើកុំព្យូទ័រ Computer នៅអាគាធំមួយដែលសព្វថ្ងៃនេះ ទៅជាឈ្មោះ Middlesex Community College ទៅហើយ តើមែនទេ?

**ឡាច ប៊ុនរិទ្ធៈ** ឡាចមែនហើយ!វ៉ាំងជាក្រុមហ៊ុនធ្វើកុំព្យូទ័រដំបូងគេបង្អស់ ខ្ញុំធ្វើការនៅទីនោះបាន១ឆ្នាំ

**ខ្មែរផុសៈ** តើនេះជាបុព្វហេតុ ដែលមានខ្មែរមកនៅឡូវែលនេះច្រើនសន្ធឹកសន្ធាប់ នោះមែនទេ?

**ឡាច ប៊ុនរិទ្ធៈ** ឡាចមិនទាន់នៅឡើយទេ! ពេល នោះខ្មែរមានតែ៥ ឬ៦០០នាក់តែប៉ុណ្ណោះតែ វ៉ាំងត្រូវការមនុស្សធ្វើការណាស់ គេហ៊ានឱ្យ៣០០ដុល្លាដល់នរណាដែលរកមនុស្សធ្វើការឱ្យគេបានម្នាក់ ហ្នឹងនៅតែរកមនុស្សមិនបានផង

**ខ្មែរផុសៈ** ចុះពេលណាទើបមានខ្មែរមកច្រើន?

**ឡាច ប៊ុនរិទ្ធៈ** ឡាចគឺចន្លោះ៨៥ នឹង ១៩៩០ នៅពេលខ្ញុំចេញពីវ៉ាំងទៅបើកហាង មានគេលក់ហាងមួយតម្លៃ៥ពាន់ដុល្លា ទំហំ១៥០០ស្កេហ្វីត តែមានតែសំបកទេ ខ្ញុំត្រូវប្រមូលរកលុយ៥ម៉ឺនទៀតដើម្បីសង់ឱ្យទៅជាហាងបើកលក់ដូរ ដាក់ឈ្មោះថា ប៉ៃលិន។ មូលហេតុដែលមានខ្មែរចូលមកនៅច្រើន ពេលនោះខ្មែរកាន់តែកើនចំនួនរៀងរាល់ថ្ងៃគឺចាប់ពី ពេលយើងពង្រីកជាបាល្លស្ទាកើតដោយ

តទៅទំព័រទី ១៦

# ក្រុងឡូវែលប្រកាសថ្ងៃ១៧មេសា ជាថ្ងៃរំលឹកសោកនាដកម្មខ្មែរ




ខ្មែរផុសស.រ.អា

ក្រុមយុវជនខ្មែរនៅសាកលវិទ្យាល័យ "យូម៉ាស់បូសតុន" រួមគ្នានឹងសកលវិទ្យាល័យ (យូម៉ាសឡូ) បានប្រារព្ធពិធីរំលឹកខួបទី៤០ឆ្នាំនៃរបបប្រល័យពូជសាស្ត្រ នៅវត្តពន្លឺពុទ្ធចក្រក្រុងឡូវែល កាលពីថ្ងៃទី១៧មេសា២០១៥នេះ។ ព្រឹទ្ធាចារ្យពុទ្ធសានិក មន្ត្រី យុវជនខ្មែរ នឹងបរទេសប្រមាណ១០០នាក់ បានមកជួបជុំគ្នាបញ្ចេញយោបល់បន្តបន្ទាប់គ្នា សម្តែងការសោកស្តាយចំពោះ របបវាលពិឃាដ ដែលបានចូលមកកាន់កាប់កម្ពុជាថ្ងៃ១៧មេសាឆ្នាំ១៩៧៥ បណ្តាលឱ្យមានការបាត់បង់ជីវិតនឹងមានទារុណកម្មធ្ងន់ធ្ងរដល់ប្រជាពលរដ្ឋរាប់លាននាក់ នឹងច្រើនលាននាក់ទៀតបន្តទទួលភាពទុរន់ទុរា ដោយជម្ងឺនឹងភាពព្រាត់ប្រាស់គ្នា រហូតដល់សព្វថ្ងៃ ។ ចំណែកឯយុវជនយុវតីខ្លះទៀត ពិពណ៌នាពីការមិនបានទទួលការពន្យល់ ពីសោកនាដកម្មដ៏ធំធេងក្នុង

តទៅទំព័រទី ២៤




# ថ្ងៃទី១៩, ខែឧសភា(ការបោះឆ្នោត នៅទីក្រុងភីឡាដែលភ្យា)

ដោយៈ Somrith Som

ប្រែសម្រួលដោយៈថាច់ វណ្ណា

ហេតុអ្វីការបោះឆ្នោតមានសារៈសំខាន់?

ពេលដែលអ្នកបានទៅបោះឆ្នោត អ្នកនិងបានបញ្ចេញសម្លេងពិតចេញពីក្នុងចិត្តរួច និងបានធ្វើការជ្រើសរើសឱ្យសមទៅតាមគំនិត ឬយោបល់របស់ខ្លួន, ថាតើខ្លួនចង់ឱ្យរដ្ឋាភិបាលធ្វើអ្វីខ្លះ?

តើអ្នកដឹកនាំមួយណាដែលខ្លួនទុកចិត្តបាន និងជ្រើសឱ្យធ្វើជាដំណាងសម្រាប់ខ្លួន, ជារៀងរាល់ពេលចុះឈ្មោះបោះឆ្នោត រួចយើងត្រូវទៅបោះឆ្នោត, បេក្ខជននយោបាយ និងពិនិត្យមើលតាមទិន្ន័យនៃអ្នកបានទៅបោះឆ្នោត, តើមានជនជាតិ អាស៊ី-អាមេរិកក្នុងក្រុង ចំនួនប៉ុន្មាននាក់ដែលបានទៅបោះឆ្នោត នោះជាកត្តានាំឱ្យមានឥទ្ធិពលនយោបាយយោងទៅតាមសន្លឹកឆ្នោត។ នៅថ្ងៃអង្គារ៍ ទី១៩ ខែឧសភា និងទី៣ ខែវិច្ឆិកាក្នុងឆ្នាំនេះ, ទីក្រុងភីឡាដែលភ្យា និងមានការបោះឆ្នោតជ្រើសរើសចៅហ្វាយក្រុង, ក្រុមប្រឹក្សាក្រុង, ចៅក្រម, គណៈកម្មាការទទួលបន្ទុកកិច្ចការបោះឆ្នោត និងភ្នាក់ងាររដ្ឋបាលផ្សេងៗ ទៀត។

ការបោះឆ្នោតសម្រាប់ក្រុងមានសារៈសំខាន់ណាស់, ព្រោះមានការជះឥទ្ធិពលលើផ្នែកនយោបាយ និងជីវភាពរស់នៅប្រចាំថ្ងៃរបស់យើង និងច្បាប់មាត្រាសម្រាប់ក្រុងនៃបុគ្គលិកក្រុមប្រឹក្សាក្រុងទាំង១០, គោលនយោបាយមួយចំនួនដែលមានភាពបះពាល់ដល់ប្រជារាស្ត្រជិតខាងក្នុងដំបន់ខ្លួនកំពុងរស់នៅ,ឧទាហរណ៍ៈ សម្រាប់ផ្នែកអនាម័យ, ការសំអាតសម្រាម,ប័ណ្ណបើកបរ, ដោះស្រាយកិច្ចការក្នុងសហគមន៏, ខាងសុវត្ថិភាព, ការផ្ដល់មូលនិធិ និងកិច្ចដំណោះស្រាយផ្សេងៗទៀត។

បុគ្គលិកទីប្រឹក្សាក្រុងពុំមានកំណត់អាណត្តិកាល និងអាចចេញឈ្មោះជាបេក្ខជនបានជាច្រើនលើក ប្រសិនជាអ្នកមានចិត្តចង់ចេញឈរឈ្មោះ។

ប្រជារាស្ត្រ អាស៊ី-អាមេរិក មានចំនួន




គ្រាប់គ្រាន់ដើម្បីផ្លាស់(ទាញ)លទ្ធផលនៃការបោះឆ្នោត, និងជួយជុំរុញសហគមន៏យើង ឱ្យទៅបោះឆ្នោត, យើងមានលទ្ធភាពទាក់ទាញអ្នកនយោបាយឱ្យស្ដាប់រាល់ដំណោះស្រាយដែលពាក់ពន្ធក្នុងសហគមន៏យើង។ និងកិច្ចអនុម័តលើគំរោងច្បាប់, ដែលអាចធ្វើឱ្យសញ្ជាតិអាមេរិក ក្នុងទីក្រុង ភីឡាដែលភ្យា មានជីវភាពប្រសើរឡើង, បើទោះជាពួកគេមិនចេះនិយាយភាសារអង់គ្លេសក៏ដោយ។

សូមជំរាបថាៈ រៀងរាល់ឆ្នាំមានការបោះឆ្នោតចំនួន២លើក, លើកទី១នៅខែ មេសាឬឧសភា,លើកទី២ជាការបោះឆ្នោតទូទៅ និងចាប់ផ្ដើមនៅខែវិច្ឆិកា, ទីក្រុងភីឡាដែលភ្យា គណបក្សប្រជាធិបតេយ្យ និងគណបក្ស សាធារណៈរដ្ឋ និងបញ្ចប់ការចុះឈ្មោះបោះលើកទី១នៅថ្ងៃទី១៩ខែឧសភា ចំពោះបេក្ខជនណាដែលបានជាប់ជំរើសមកពីគណះបក្សទាំងពីរ គេនិងបន្តធ្វើការបោះឆ្នោតលើកទី២នៅថ្ងៃទី៣,ខែវិច្ឆិការខាងមុខសម្រាប់រាល់មុខដំណែងក្នុងរដ្ឋបាល។

ប្រសិនជាអ្នកមិនចេះនិយាយភាសាអង់គ្លេស, អ្នកអាចនាំអ្នកបកប្រែ ឬអ្នកគ្រួសារទៅបោះឆ្នោតជាមួយ ប្រសិនជាលោកអ្នកត្រូវការជំនួយក្នុងការចុះឈ្មោះ ឬមើលបញ្ជីឈ្មោះបោះឆ្នោត ឬរកទីកន្លែងបោះឆ្នោត, ត្រូវការអ្នកបកប្រែក្នុងថ្ងៃបោះឆ្នោត សូមទាក់ទង និងលោកៈ សមសម្រឹត, ទូរស័ព្ទលេខៈ២៦៧-៩៧៤-០២៣៩, ឬចូលគេហទំព័ររកព័តិមានបន្ថែមតាមរយះវែបសាយៈ www.philadelphiavotes.com, អ៊ីម៉ែលៈ somrith.som@gmail.com.

# MAY 19TH - WHY VOTING IS IMPORTANT

When you vote, you are making your voice heard and registering your opinion on how you think the government



should operate and which leaders should represent you. Everytime we register to vote and we vote, politicians see data on how many Asian Americans in the city vote and we gain political influence and power.

On Tuesday May 19th and November 3rd this year, the Philadelphia will be voting for our new Mayor, City Council, Judges, City Commissioners (an office that facilitates the election process), and other local city government positions. City elections are very important because these local politicians affect our day to day lives and the policies in the city. The 10 District City Council members, for example, are the politicians that have direct impact in our neighborhoods when it comes to sanitation, trash collection, permits and licenses, community issues, safety, distribution of funds, and other issues. City Council members also do not have term limitations and can run as many times as they want.

There are enough Asian American voters in the city to change the results of en election. If Asian Americans voted and helped our community to vote, we have the power to influence politicians to listen to the issues and concerns of our community and to enact legislation that will promote the well-being of all Philadelphia's citizens, whether or not they speak English.

Did you know? There are 2 elections every year, the primary elections in April or May and the general elections in the beginning of November. Philadelphia has a closed primary election process, which means that if you are a registered Democrat, you vote between the Democratic candidates during the May primary elections, and if you are registered as a Republican, you vote between the Republican candidates in May. The candidate with the highest amount of votes from each party after May 19th will battle it out on November 3rd elections. On November 3rd, you can vote for either candidate, no matter what party they are in. This applies for every government position.

If you do not speak English, you can bring an interpreter or family member with you to the polls. If you or someone you know need help registering to vote, checking on your registration status, finding your voting location, need interpretation assistance on voting day, or have other questions, visit www.philadelphiavotes.com or please contact:

Somrith Som (267) 974-0239 | somrith.som@gmail.com

តមកពីទំព័រទី ០១ ## ទឹករងថ្លាទើបឃើញ...

ចេញពីការឃុបឃិត រវាង គ.ជ.ប.ចាស់ នឹង គណបក្សប្រជាជនកម្ពុជា។ អំណាចដែលគណបក្សប្រជាជនចង់កាន់បន្តរប្រកបដោយល្បិច ធ្វើឱ្យគួរប្រកួតប្រឆាំង រួមទាំងប្រជាជាតិ តស៊ូប្រយុទ្ធយ៉ាងស្វិតស្វាញ បោសសំអាតបរិយាកាសល្បិចនយោបាយ...ចាប់តាំងពីពេលនោះមក បឹងនយោបាយខ្មែរ បានត្រូវល្អក់ នឹង អាប់អួរយ៉ាងខ្លាំង។

ដើម្បីយល់បុព្វហេតុនៃការកកូរទឹកឱ្យល្អក់នោះ គេអាចចែកបរិយាកាសអាប់អួរនោះជា២វគ្គបានៈ

**វគ្គទី១-** គឺការតវ៉ា សម្ដែងមតិ ធ្វើបាតុកម្ម ដឹកនាំដោយគណបក្សសង្គ្រោះជាតិ ដោយចលនាកម្មករ ដោយចលនាសកម្មជនដីធ្លី ដោយចលនាគ្រូបង្រៀន... ដែលចេះតែរីកធំទៅ ចាប់តាំងពីរាប់ពាន់នាក់ រហូតដល់រាប់ម៉ឺន នឹងរាប់លានថែមទៀត ដែលរូបភាពនេះបានក្លាយជាកម្លាំងប្រជាជន គាំទ្រគណបក្សសង្គ្រោះជាតិដ៏ច្រើនមិនដែលមានពីមុនមកទាមទារឱ្យ **"បង្ហាញលទ្ធផលបោះឆ្នោតត្រឹមត្រូវ"** នឹងមិនទទួលស្គាល់ថា **"អ្នក**

**តទៅទំព័រទី ១៦**



# ដំណើរទស្សនកិច្ចលោក អាឡិចស៍ រញ្ជួយសហគមន៍ខ្មែរ នៅអាមេរិក

ដោយៈ ស្វាយ បុណ្យ

**ឡូវែលៈ** សហគមន៍ខ្មែរនៅឡូវែល ប្រមាណ៣០០នាក់បានរៀបចំពិធីស្វាគមន៍ ដល់ជនជាតិអេស្ប៉ាញម្នាក់មកពីកម្ពុជា ដែលជាសកម្មជនការពារព្រៃឈើខ្មែរ កាលពីថ្ងៃសៅរ៍ ទី៤មេសាកន្លងទៅ ដោយមានលោកអភិបាលក្រុងឡូវែលចូលរួមផង ។

តើអាឡិចស៍ ជានរណា? ហេតុអ្វី បានជាសហគមន៍ខ្មែរនៅអាមេរិក បាក់ចិត្តគាំទ្រគាត់ខ្លាំងម្ល៉េះ?


លោក អាឡិចស៍ ហ្គុងសាឡេស ដេវីតសុន ទទួលការកោតសរសើរពីអភិបាលក្រុងឡូវែល

លោក អាឡិចស៍ ហ្គុងសាឡេស ដេវីតសុន ជាជនជាតិអេស្ប៉ាញ កើតនៅឆ្នាំ ១៩៨០ នៅក្រុងបាសេឡូណា ។ គាត់រស់នៅប្រទេសអេស្ប៉ាញបាន ១៦ ឆ្នាំ ។ បន្ទាប់មក គាត់បានទៅតាមម្ដាយទៅរស់នៅប្រទេសអង់គ្លេស ។ ក្រោយពីរៀនចប់វិទ្យាល័យនៅប្រទេសអង់គ្លេស គាត់បានទៅរស់នៅប្រទេសថៃឡង់ដ៍បានមួយឆ្នាំ ។ ប៉ុន្តែ គាត់មិនចូលចិត្តការរស់នៅក្នុងប្រទេសថៃឡង់ដ៍ ។

នៅឆ្នាំ ២០០២ គាត់បានទៅកាន់ប្រទេសកម្ពុជា ។ ចាប់ពីពេលនោះមក គាត់បាក់ចិត្តស្រលាញ់ស្រុកខ្មែរ ដកចិត្តមិនរួច ។ ដំបូង គាត់ធ្វើជាគ្រូបង្រៀនភាសាអង់គ្លេស ។ ក្នុងពេលគាត់កំពុងធ្វើជាគ្រូបង្រៀនភាសាអង់គ្លេសនេះ គាត់បានឆ្លៀតឱកាសធ្វើដំណើរទៅលេងតំបន់ព្រៃភ្នំ និង សហគមន៍ជនជាតិដើមភាគតិច ។

ក្នុងឆ្នាំ ២០០៨ គាត់រកការងារបានធ្វើជាអ្នកបកប្រែភាសា ។ នៅពេលនោះ គាត់ចាប់ផ្ដើមសង្កេតឃើញវិនាសកម្ម និងការបំផ្លិចបំផ្លាញធនធានធម្មជាតិខ្មែរយ៉ាងដំណំ ។ គាត់គិតថា បើគ្មានការចាត់វិធានការការពារបន្ទាន់ ធនធានធម្មជាតិចុងក្រោយនៅប្រទេសកម្ពុជា នឹងរលាយសូន្យគ្មានសល់សម្រាប់ក្មេងជំនាន់ក្រោយ ។

ក្នុងឆ្នាំ ២០១១ គាត់រកបានការងារថ្មីមួយទៀត ជាអ្នកបកប្រែក្នុងប្រព័ន្ធពន្ធនាគារ ។ ពេលនោះគាត់ធ្វើជាអ្នកឃ្លាំមើលផ្នែកសិទ្ធិមនុស្សផងដែរ ។ ក្នុងឆ្នាំ ២០១២ ក្រោយពីបានសន្សំប្រាក់ខ្លះពីការបង្រៀនភាសាអង់គ្លេស និងបកប្រែភាសា គាត់បានយកប្រាក់សន្សំទាំងនោះ ទៅបង្កើតចលនាមួយឈ្មោះថា ចលនាមាតាធម្មជាតិ ។ គោលបំណងក្នុងការបង្កើតចលនានេះ គឺដើម្បីបញ្ឈប់កុំឱ្យរដ្ឋាភិបាលកម្ពុជាបំផ្លិចបំផ្លាញធនធាតុធម្មជាតិ និង ប្រព័ន្ធបរិស្ថានធម្មជាតិ និងអេកូឡូស៊ី ។

លោកអេឡិចស៍ មានប្រសាសន៍ជាភាសាខ្មែរ យ៉ាងច្បាស់លាស់ថាៈ "ធនធានធម្មជាតិរបស់ខ្មែរយើង ត្រូវរងការបំផ្លិចបំផ្លាញដោយគ្មានបន្ធូរដៃ ក្រោមលេសអភិវឌ្ឍន៍ បង្កើតការងារធ្វើ កាត់បន្ថយភាពក្រីក្រ ជាដើម ។ល។" ។

លោកបន្តថា "តាមការពិតអ្នកដែលបានផលចំណេញ គឺមានតែមន្ត្រី និងអ្នកមានកប់ក្ដោងតែមួយក្ដាប់តូចប៉ុណ្ណោះ ។ ផ្ទុយទៅវិញ ទង្វើបំផ្លិចបំផ្លាញធនធានធម្មជាតិនេះ ធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅ និងអាយុជីវិតប្រជាជនខ្មែររាប់លាននាក់ ដែលពួកគាត់រស់អាស្រ័យលើប្រព័ន្ធអេកូឡូស៊ី និងបរិស្ថានធម្មជាតិល្អបរិសុទ្ធ" ។

លោកបញ្ជាក់ទៀតថា យុទ្ធនាការដំបូងរបស់ពួកគាត់ គឺប្រយុទ្ធប្រឆាំងគម្រោងសង់ទំនប់វ៉ារីអគ្គិសនីដ៏ធំមួយ ។ ការសង់ទំនប់នេះនឹងអាច

តទៅទំព័រទី ០៩







តមកពីទំព័រទី ០៨

# ដំណើរទស្សនកិច្ចលោក អាឡិចស៊ី...



ធ្វើឱ្យជន់លិចតំបន់ព្រៃអារ៉ែងនៅក្នុងខេត្តកោះកុង។ យុទ្ធនាការរបស់ពួកគាត់ បានទទួលជោគជ័យ ដោយសារគម្រោងសង់ទំនប់វ៉ារីអគ្គិសនីនោះ ទំនងជាបានផ្អាកដំណើរការហើយនៅពេលនេះ។ ប៉ុន្តែ ជាអកុសល គាត់ត្រូវបានរដ្ឋាភិបាលបណ្ដេញចេញពី ប្រទេសកម្ពុជាដែលលោកអាឡិចស៊ី បានចាត់ទុកថាជាមាតុភូមិរបស់គាត់ផងដែរ។

លោកអាឡិចស៊ី អះអាងថា ទោះបីលោកត្រូវនិរទេសខ្លួន មកនៅក្រៅប្រទេសកម្ពុជាក្ដីការតស៊ូរបស់ចលនាមាតាធម្មជាតិរបស់លោកនៅតែបន្តទៅមុខ ដោយឥតរាថយឡើយ។ លោកថា បេសកកម្មការពារសម្បត្តិធម្មជាតិខ្មែរនៅតំបន់អារ៉ែង នឹងនៅតែសកម្មបន្តទៀត។

តើហេតុអ្វីបានជារដ្ឋាភិបាលលោក ហ៊ុន សែន បណ្ដេញ អាឡិចស៊ី?

នៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ រដ្ឋាភិបាលលោក ហ៊ុន សែន បានបណ្ដេញលោកអាឡិចស៊ី ចេញពីប្រទេសកម្ពុជា តាមជើងយន្តហោះមួយឆ្ពោះទៅកាន់ប្រទេសអេស្ប៉ាញ។ ប៉ុន្តែដោយសារការស្រលាញ់ជាប់ចិត្តនិងស្រុកខ្មែរ និងចង់បន្តបេសកកម្មថែរក្សាធនធានធម្មជាតិខ្មែរបន្ត គាត់បានវិលទៅស្នាក់នៅប្រទេសថៃឡង់ដ៏ដើម្បីបាននៅជិតក្រុមការងាររបស់គាត់នៅខ្មែរ និងបានបន្តទំនាក់ទំនងជាមួយក្រុមការងាររបស់គាត់ជាប្រចាំ។

តាមសម្ដីលោក អាឡិចស៊ី មូលហេតុដែលនាំឱ្យរដ្ឋាភិបាលលោក ហ៊ុន សែន បណ្ដេញគាត់គឺដោយសារគាត់ជាឆ្អឹងទទឹង-ករដ្ឋាភិបាល។ សកម្មភាពការពារបរិស្ថានធម្មជាតិរបស់ចលនាមាតាធម្មជាតិ ដែលគាត់ដឹកនាំ ធ្វើឱ្យរាំងស្ទះដល់គម្រោងសាងសង់ទំនប់វ៉ារីអគ្គិសនីរបស់ក្រុមហ៊ុនចិន ស៊ីណូហៃដ្រូ និងរារាំងដល់ការកាប់បំផ្លាញព្រៃឈើ និង ធនធានធម្មជាតិនៅតំបន់អារ៉ែង។ ម្យ៉ាងទៀត អ្នកវិភាគមើលឃើញថា រដ្ឋាភិបាលសម្លឹងឃើញសកម្មភាពរបស់ អាឡិចស៊ីថាជាទង្វើគ្រោះថ្នាក់ ប៉ះពាល់ដល់កេរ្តិ៍ឈ្មោះដែលមិនល្អស្រាប់របស់រដ្ឋាភិបាលបច្ចុប្បន្ន។

នរណាក៏ដឹងថា ក្រោមការដឹកនាំរបស់លោក ហ៊ុន សែន ធនធានធម្មជាតិស្រុកខ្មែររលាយហិនហោចអស់ស្ទើរគ្មានសល់។ សកម្មជនបរិស្ថាន និង ព្រៃឈើដែលហ៊ានក្រោកតវ៉ា តស៊ូមតិកុំឱ្យគេបន្តកាប់បំផ្លាញព្រៃឈើ និង ធនធានធម្មជាតិ បើមិនជាប់គុក ក៏ត្រូវគេបាញ់សម្លាប់ចោលដែរ។ លោក ឈុត វុទ្ធី ដែលជាសកម្មជនការពារព្រៃឈើដ៏ល្បីល្បាញមួយរូប ត្រូវបានទាហានរដ្ឋាភិបាលលោក ហ៊ុន សែន បាញ់ស្លាប់នៅក្នុងខេត្តកោះកុង កាលពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ ដោយសារតែគាត់មិនព្រមប្រគល់ឧបករណ៍រក្សាទុករូបថត ដែលគាត់ថតបាន អំពីសកម្មភាពកាប់បំផ្លាញព្រៃឈើក្នុងខេត្តកោះកុង។ លោក ហង់ សិរីឧត្ដម អាយុ ៤២ ឆ្នាំ ជាអ្នកយកព័ត៌មានអំពីការការឈើខុសច្បាប់ ដែលពាក់ព័ន្ធនឹងក្រុមអភិជនពុករលួយ ត្រូវបានគេសម្លាប់ញាត់ក្នុងគូទឡាន កាលពីថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១២ នៅក្នុងខេត្តរតនគិរី។ កាលពីថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៤ អ្នកកាសែតម្នាក់ទៀតឈ្មោះលោក តាំង ទ្រី អាយុ ៤៩ ឆ្នាំ ត្រូវបានគេបាញ់សម្លាប់នៅខេត្តក្រចេះ ដោយសារគាត់ស៊ើបអង្កេតការកាប់ឈើខុសច្បាប់នៅភាគខាងកើតនៃប្រទេសកម្ពុជា។

ឥឡូវដល់វេនលោក អាឡិចស៊ីម្ដង។ មុនរដ្ឋាភិបាលខ្មែរបណ្ដេញគាត់ចេញពីស្រុកខ្មែរ។ រដ្ឋាភិបាលឈប់បន្តទិដ្ឋាការស្នាក់នៅបន្តឱ្យគាត់។ លោក អាឡិចស៊ី ចាត់ទុកថា រឿងនោះជារឿងចម្លែក ព្រោះអីគាត់រស់នៅស្រុកខ្មែរជិត ១៣ ឆ្នាំមកហើយ មិនដែលមានបញ្ហាបន្តទិដ្ឋាការស្នាក់នៅនេះទេ។ ប៉ុន្តែ រដ្ឋាបាលចោទប្រកាន់ថាគាត់ប្រព្រឹត្តបំពានច្បាប់ខ្មែរ នៅពេលពួកគាត់លើកគ្នាក្នុងសហគមន៍តំបន់អារ៉ែង បិទផ្លូវមិនឱ្យមន្ត្រីរដ្ឋាភិបាល ចូលទៅតំបន់អារ៉ែង។ លោកអាឡិចស៊ី ចាត់ទុកថា នេះគ្រាន់តែជាលេសរបស់រដ្ឋាភិបាលប៉ុណ្ណោះ ព្រោះអីប្រជាជននៅសហគមន៍មិនចង់ឱ្យពួកក្រុមហ៊ុនចិនស៊ីណូហៃដ្រូ ចុះទៅបំផ្លាញធនធានធម្មជាតិរបស់ពួកគេ។ ហេតុដូចនេះ ទើបពួកគេបិទផ្លូវមិនឱ្យពួកទាំងនេះចូល។

ដោយសាររដ្ឋាភិបាលមិនបន្តទិដ្ឋាការ ការស្នាក់នៅដោយស្របច្បាប់របស់លោក អាឡិចស៊ីត្រូវអស់សុពលភាពនៅក្នុងខែកុម្ភៈ។ ដំបូងរដ្ឋាភិបាលណែនាំឱ្យគាត់ចេញទៅក្រៅប្រទេសមួយរយៈ រួចហើយសឹមត្រឡប់មកវិញម្ដងទៀត។ ប៉ុន្តែលោក អាឡិចស៊ី ស្គាល់ចរិតរដ្ឋាភិបាលលោក ហ៊ុន សែន ច្បាស់។ គាត់ថា បើគាត់ចេញពីកម្ពុជា រដ្ឋាភិបាលនឹងមិនអនុញ្ញាតឱ្យគាត់ចូលវិញទេ។ គាត់សុខចិត្តបន្តស្នាក់នៅទាំងទិដ្ឋាការស្នាក់នៅផុតកំណត់។ គាត់ថា គាត់នឹងមិនទៅណាទេ ព្រោះកម្ពុជាជាមាតុភូមិរបស់គាត់។ ភ្លាមនោះ រដ្ឋាភិបាលបានចាប់បញ្ជូនគាត់ជាបន្ទាន់ និងបានបោះត្រាលើលិខិតឆ្លងដែនគាត់ ដោយចារហាមចូលប្រទេសកម្ពុជា ដោយគ្មានកំណត់។

នៅក្នុងកម្មវិធីជួបសំណេះសំណាលបងប្អូនខ្មែរ-អាមេរិកនៅក្រុងឡូវែល កាលពីដើមខែមីនា លោក អាឡិចស៊ី ដែលនិយាយខ្មែរច្បាស់គ្មានទាក់មួយម៉ាត់ បានបង្ហាញអំពីការប្ដេជ្ញាចិត្តបន្តបេសកកម្មការពារបរិស្ថានធម្មជាតិខ្មែរទៅទៀត។ គាត់រំភើបក្នុងចិត្តយ៉ាងក្រៃលែង ដែលបានទទួលការស្វាគមន៍ និងគាំទ្រយ៉ាងខ្លាំងពីសំណាក់បងប្អូនខ្មែរ-អារិក។ គាត់ថា ការគាំទ្រដ៏

តទៅទំព័រទី ១៥




# លោក ហ៊ុន សែន ប្រាប់លោក សម រង្ស៊ី កុំឱ្យមានគំនិតសង្រ្គាម

ឌី ខាំបូឌាដែលី
ដោយៈ ហ៊ុល រស្មី | April 27, 2015



លោក សម រង្ស៊ី មេដឹកនាំគណបក្សប្រឆាំងស្តាប់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន អំឡុងពេលកិច្ចប្រជុំនៅក្រុងកូឡាឡាំពួរ កាលពីថ្ងៃសៅរ៍ នៅក្នុងរូបថតដែលបោះផ្សាយដោយភ្នាក់ងារសារព័ត៌មានកម្ពុជា។

នៅក្នុងកិច្ចប្រជុំជាសាធារណៈដ៏ពិសេសមួយជាមួយលោក សម រង្ស៊ី មេដឹកនាំគណបក្សប្រឆាំងនៅក្នុងទីក្រុងគូឡាឡាំពួ កាលពីថ្ងៃសៅរ៍ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានទទួលស្គាល់ថា លោក សម រង្ស៊ី អាចនឹងជំនួសលោកនៅក្នុង ២០១៨ ប៉ុន្តែបានព្រមានថា **"កងកម្លាំង"** ដែលស្មោះស្ម័គ្រនឹងគណបក្សប្រជាជនកម្ពុជានឹងរារាំងមិនឱ្យកើតមានទង្វើសង្គ្រាមណាមួយឡើយ ប្រសិនបើលោក សម រង្ស៊ី គ្រោងធ្វើដូច្នេះនោះ។

លោក ហ៊ុន សែន បានលើកឡើងពេលថ្លែងនៅក្នុងព្រឹត្តិការណ៍ផ្លូវការមួយរវាងមេដឹកនាំទាំងពីរនៅសណ្ឋាគារ Hilton Double Tree ក្នុងទីក្រុងគូឡាឡាំពួថា លោក សម រង្ស៊ី នឹងមិនអាចគេចផុតពីផលប៉ះពាល់បានឡើយ ប្រសិនបើលោកឡើងកាន់អំណាច ហើយបន្ទាប់មកចាប់ផ្តើមធ្វើបាបអ្នកកាន់តំណែងមុនលោកនោះ។

លោក ហ៊ុន សែន បានមានប្រសាសន៍នៅចំពោះមុខពលរដ្ឋខ្មែរប្រហែល២០០នាក់ក្នុងប្រទេសម៉ាឡេស៊ីពេលអង្គុយជាប់លោក សម រង្ស៊ី ថា **"ឥឡូវនេះខ្ញុំនៅធ្វើនាយករដ្ឋមន្ត្រី ទាំងអស់គ្នានៅជាមួយគ្នាបាន ប៉ុន្តែស្រាប់តែដល់ពេលណាមួយស្រាប់តែឯកឧត្តម សម រង្ស៊ី ធ្វើជានាយករដ្ឋមន្ត្រីម្តង ឧទាហរណ៍ទេណា! ស្រាប់តែដល់ពេលហ្នឹងឯកឧត្តមអត់ឱ្យខ្ញុំរស់នៅ ស្រាប់តែទៅធ្វើបាបខ្ញុំ ហើយខ្ញុំមានកងកម្លាំងដែលអាចវាយបកវិញ នោះវានឹងធ្វើឱ្យឯកឧត្តមក៏មិនអាចរស់នៅបានដែរ"** ។

លោក ហ៊ុន សែន ក៏បានរិះគន់ខ្លាំងៗចំពោះអ្នករិះគន់ **"វប្បធម៌នៃការសន្ទនា"** ដែលលោក និងលោក សម រង្ស៊ី បានផ្សព្វផ្សាយចាប់តាំងពីមានភាពរីកចម្រើនផ្នែកនយោបាយកាលពីឆ្នាំមុនមក។ មេដឹកនាំទាំងពីរចាត់ទុកវប្បធម៌នៃការសន្ទនានេះជាការបញ្ចប់វប្បធម៌នយោបាយហិង្សា ដែលកើតមកជាយូរមកហើយនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែអ្នករិះគន់បានលើកឡើងថា លោក ហ៊ុន សែន ឱ្យតម្លៃដល់វប្បធម៌នៃការសន្ទនានេះគឺគ្រាន់តែនៅពេលវាផ្តល់ប្រយោជន៍ដល់លោកប៉ុណ្ណោះ។

លោកនាយករដ្ឋមន្ត្រីបានអំពាវនាវឱ្យមានភាពអត់ធ្មត់ ដោយលើកឡើងថា មានតែពេលវេលាទេ ដែលនឹងអាចប្រាប់ថា តើវប្បធម៌ថ្មីនេះពិត ឬយ៉ាងណា? ។

**តទៅទំព័រទី ១១**

**WELL GIVEN AFC**
**30 Eastbrook Rd., suite#404**
**Dedham, MA 02026**
**781-320-0855**
**wellgivenadultfamilycare.com**

**លោកអ្នកកំពុងរស់នៅជាមួយមនុស្សជាទីស្រលាញ់ និង កំពុងមើលថែគាត់ឬ?**
**សូមកុំបារម្ភ!**

**WELL GIVEN AFC មានផ្តល់សេវា ដើម្បីជួយលោកអ្នកបាន។**
សូមទូរស័ព្ទមកលេខៈ **781-320-0855**ថ្ងៃ ច័ន្ទ ដល់ ថ្ងៃ សុក្រ ចាប់ពីម៉ោង ៩ ព្រឹក ដល់ ៥ ល្ងាច ឬ សូមបើកមើលគេហទំព័ររបស់យើងៈ **http://www.wellgivenadultfamilycare.com/**

យើងខ្ញុំទទួលបានសិទ្ធិអនុញ្ញាតពី **MassHealth**ដើម្បីផ្តល់សេវាទូទាំងរដ្ឋម៉ាសាឈូសេត។ ទន្ទឹមនឹងនេះ យើងខ្ញុំមានផ្តល់សេវាគ្រប់គ្រងករណី និង ជំនួយផ្នែកថែទាំ។ អ្នកមើលថែទាំងអស់ សុទ្ធតែទទួលបានប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ ស្របតាមក្រមនៃបទប្បញ្ញត្តិ (CMR) រដ្ឋម៉ាសាឈូសេត។

កម្មវិធីលើកកម្ពស់ការថែទាំមនុស្សពេញវ័យ **Well Given Adult Foster Care (AFC)**ជាកម្មវិធីជម្រុះមួយ ដែលផ្តល់សេវាជូនអ្នកទាំងឡាយណាៈ
- ដែលមានអាយុចាប់ពី ១៦ ឆ្នាំ
- ដែលរស់នៅក្នុងផ្ទះឯកជន មានអ្នកមើលថែផ្ទាល់ខ្លួន
- ដែលមានប័ណ្ណធានារ៉ាប់រងសុខភាព MassHealth (ប្រភេទ Standard ឬCommonHealth) ឬ Fallon Total Care-Navicare
- ដែលមានគ្រូពេទ្យខ្លួនម្នាក់ (PCP) សម្រាប់មើលថែក្នុងពេលបច្ចុប្បន្ន
- មានសិទ្ធិទទួលបានសេវាលើកកម្ពស់ការថែទាំមនុស្សពេញវ័យ (AFC)



ក្រុមអ្នកឯកទេសជម្រុះរបស់កម្មវិធី ***Well Given Adult Foster Care*** រួមមានៈ
- អ្នកគ្រប់គ្រងករណី AFC/បុគ្គលិកសង្គមកិច្ច
- គិលានុបដ្ឋាករបស់ AFC ដែលរៀនចប់កម្មវិធីថែទាំសុខភាព
- អ្នកមើលថែរបស់ AFC ដែលអាចជាសមាជិកគ្រួសាររបស់អ្នក

ព័ត៌មានផ្សេងៗទៀតអំពីកម្មវិធីលើកកម្ពស់ការថែទាំមនុស្សពេញវ័យ ***Well Given Adult Foster Care***ៈ
- កម្មវិធីនេះដំណើរការ និង គ្រប់គ្រងដោយអ្នកជំនាញវិជ្ជាជីវៈផ្នែកថែទាំសុខភាព ដែលមានអាជ្ញាប័ណ្ណ និង មានបទពិសោធន៍លើសពី ២៥ ឆ្នាំ និង មានបទពិសោធន៍ផ្នែកគ្រប់គ្រងក្នុងវិស័យសុខាភិបាល។
- បុគ្គលិករបស់យើងខ្ញុំចេះនិយាយជាង ៨ ភាសា មានដូចជា ភាសាអង់គ្លេស រុស្ស៊ី បារាំង ភាសា Creole ចិន វៀតណាម អេស្ប៉ាញ អាមេនី រ៉ូម៉ានី។

**សាលាថែទាំកុមារឡូវែល**
**LOWELL DAY NURSERY ASSOCIATION**
119 HALL STREET
LOWELL, MASS.01854
**978-454-5981**

- កំពុងបើកទទួលសិស្សានុសិស្សកុមារអាយុ១៥ខែ រហូតដល់២ឆ្នាំ៩ខែ
- សាលាមុនថ្នាក់មត្តេយ្យ
- មានបុគ្គលិកប្រកបគរុកោសល្យល្អ
- ជាសាលាល្អចំណាត់ថ្នាក់ប្រចាំឆ្នាំ

- OPENINGS AVAILABLE! TODDLERS -15 MONTHS THRU 2YEARS 9 MONTHS
- PRESCHOOL AND KINDERGARTEN
- GREAT CURRICULUM WITH SEASONED STAFF
- NATIONAL DIRECTOR OF THE YEAR

www.lowelldaynursery.com
or Like us on Facebook – Lowell Day Nursery Association





តមកពីទំព័រទី ១០

# លោក ហ៊ុន សែន ប្រាប់លោក សម រង្ស៊ី...

លោក ហ៊ុន សែន បានមានប្រសាសន៍ថា **"សូមរង់ចាំមើលសិន។ ប្រសិនបើយើងមិនចុះទឹកទេ យើងនឹងមិនដឹងថា ត្រូវហែលទឹកដូចម្តេចឡើយ ហើយមិនដឹងថា តើវាជ្រៅ ឬក៏រាក់ ក្តៅ ឬត្រជាក់ឡើយ"**។

លោក សម រង្ស៊ី ដែលបានទៅដល់ប្រទេសម៉ាឡេស៊ី កាលពីសប្តាហ៍មុនជាមួយសមាជិកសភាមកពីគណបក្សប្រឆាំងមួយចំនួនទៀតសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សានៃអ្នកប្រជាធិបតេយ្យសេរីអាស៊ីបានសាទរចំពោះភាពរីកចម្រើននៃទំនាក់ទំនងរវាងលោក និងលោកនាយករដ្ឋមន្ត្រី។

លោក សម រង្ស៊ី បានមានប្រសាសន៍នៅក្នុងកិច្ចប្រជុំជាមួយលោក ហ៊ុន សែន ថា **"នេះគឺជានិមិត្តរូបនៃការរួបរួមជាតិ។ អ្វីដែលយើងបានចាប់ផ្តើមរវាងលោក ហ៊ុន សែន និងខ្ញុំ គឺត្រូវចាប់ផ្តើមវប្បធម៌នៃការសន្ទនា ដែលជាទំព័រប្រវត្តិសាស្ត្រថ្មីផ្នែកនយោបាយនៅក្នុងឆាកនយោបាយកម្ពុជា "**។ លោកបានមានប្រសាសន៍ថា **"ឥឡូវនេះ សហគមន៍អន្តរជាតិ ប្រទេសជិតខាងរបស់យើង និងអ្នកកាសែតកំពុងសំដែងការគាំទ្រ ការសរសើរ ហើយទទួលស្គាល់ថា ឥឡូវខ្មែរយើងដឹងអំពីរបៀបស្វែងរកវិធីសាស្ត្រដើម្បីពិភាក្សា និងគោរពគ្នាទៅវិញទៅមកហើយ"**។

លោក សម រង្ស៊ី បានអះអាងថា **"មានប្រទេសជាច្រើនបាននិយាយថា ពួកគេចង់យកកម្ពុជាជាគំរូ"**។

**"វប្បធម៌នៃការសន្ទនា"** ថ្មីមួយត្រូវបានប្រកាសឡើងជាលើកដំបូងដោយលោក សម រង្ស៊ី បន្ទាប់ពីភាពរីកចម្រើនផ្នែកនយោបាយស្រដៀងគ្នានេះជាមួយលោក ហ៊ុន សែន កាលពីខែកុម្ភៈ ឆ្នាំ២០០៦ ប៉ុន្តែទីបំផុតវាបានរលាយសាបសូន្យទៅវិញ ដោយលោក សម រង្ស៊ី បានភៀសខ្លួនទៅប្រទេសបារាំងអស់រយៈពេលបីឆ្នាំបន្ទាប់ពីត្រូវបានចោទប្រកាន់ពីបទល្មើសមួយចំនួនពាក់ព័ន្ធនឹងការដកបង្គោលព្រំដែន។

ទោះបីជាយ៉ាងដូច្នេះក្តី តែកាលពីថ្ងៃសៅរ៍ លោក សម រង្ស៊ី ក៏បានអំពាវនាវស្រដៀងនឹងការអំពាវនាវរបស់លោក ហ៊ុន សែន ដែលស្នើឱ្យមានការអត់ធ្មត់ដែរ ខណៈវប្បធម៌នៃការសន្ទនាកំពុងរីកចម្រើន។

លោកបានមានប្រសាសន៍ថា **"យើងបានឃើញវត្តមានរបស់អ្នកកាសែត ដែលបានតាមដានយើងរហូតមក។ ពួកគេកំពុងឆ្ងល់ថា តើយើងអនុវត្តវប្បធម៌នៃការសន្ទនាពិតប្រាកដ ឬលេងសើច"**។

មេដឹកនាំគណបក្សប្រឆាំងរូបនេះបានមានប្រសាសន៍បន្ថែមទៀតថា **"សូមរង់ចាំមើលសិន។ វានឹងមានភាពរីកចម្រើនកាន់តែខ្លាំងឡើង"**។

លោក គល់ បញ្ញា នាយកប្រតិបត្តិគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) បានលើកឡើងថា វាគ្មានអ្វីប្លែកទេសម្រាប់ លោក ហ៊ុន សែន ដែលសន្យាថា នឹងមានការផ្ទេរអំណាចនៅពេលប្រឈមនឹងការប្រឆាំងដ៏ខ្លាំងក្លា ហើយក្រោយមកធ្វើការរិះគន់ និងអះអាងពីភាពខ្លាំងរបស់ខ្លួនសាជាថ្មីនោះ។

លោកបានមានប្រសាសន៍ថា **" លោក ហ៊ុន សែន ធ្លាប់បាននិយាយជាច្រើនលើក ច្រើនសាបែបនេះជាមួយលោក សម រង្ស៊ី រួចមកហើយដូចជានៅក្នុងឆ្នាំ២០០៦ជាដើម ដោយលោកលើកឡើងថា លោកនឹងផ្ទេរអំណាចប្រសិនបើ លោកចាញ់ឆ្នោត ប៉ុន្តែបន្ទាប់មកលោកព្យាយាមគ្រប់គ្រង និងដាក់សម្ពាធផ្នែកនយោបាយ។ វាមិនមែនជាលើកទី១ទេដែលបញ្ហានេះបានកើតឡើង។ វាកើតឡើងនៅពេលលោកត្រូវការចរចា"**។

នៅក្នុងសន្ទរកថាមួយពីរខែមុនការបោះឆ្នោតជាតិលើកចុងក្រោយ លោក ហ៊ុន សែន បានប្តេជ្ញាថា នឹងធ្វើជានាយករដ្ឋមន្ត្រីរហូតដល់អាយុ៧៤ឆ្នាំ ប៉ុន្តែ លោក បានដកពាក្យសម្តីនេះវិញកាលពីខែមីនា ដោយលើកឡើងថា វាគ្រាន់តែជាកំហឹងមួយពេលរបស់លោកប៉ុណ្ណោះ។

លោក គល់ បញ្ញា បានលើកឡើងថា ការគំរាមប្រើកម្លាំងជាសាធារណៈរបស់លោក ហ៊ុន សែន ឥឡូវនេះអាចងាកទៅខាំលោកវិញ ប្រសិនបើការក្តោបអំណាចរបស់លោកមិនធ្លាក់ចុះ នៅក្នុងការបោះឆ្នោតជាតិនៅក្នុងឆ្នាំ២០១៨ទេនោះ។

លោកបានមានប្រសាសន៍ថា **"លោកមិនគួរគំរាមសងសឹកដោយប្រើយោធា ឬអ្វីផ្សេងណាមួយឡើយ ហើយគួរតែដកពាក្យសម្តីបែបនេះចេញដើម្បីកុំធ្វើឱ្យពលរដ្ឋមានអារម្មណ៍សុវត្ថិភាពជាងមុន និងមានការអត់ឱន"**។

លោកបានមានប្រសាសន៍បន្ថែមទៀតថា **"លោកស្មានថាអ្វីៗនៅតែស្ថិតក្រោមការគ្រប់គ្រងរបស់លោក ប៉ុន្តែ វាប្រហែលជាមិនពិតឡើយ។ មានតែការគាំទ្រ និងការអត់ឱនរបស់ពលរដ្ឋទេដែលអាចធានាសុវត្ថិភាពរបស់លោកបាន"**៕

ស៊ុយឈាង (រាយការណ៍បន្ថែមដោយ Alex Willemyns)



# ឆ្នាំមមែក្នុងទំនាយមហាសង្ក្រាន្ត


លោក អ៊ឹម ប៊ុរិន្ទ

**តមកពីលេខមុន**

មនុស្សផងទាំងឡាយនឹងកើតទុក្ខសោក រោគភ័យ ស្លាប់ព្រោះជំងឺ និងមានកលិយុគ សង្គ្រាមច្បាំងគ្នា ។ ផែនដីនឹងស្ងួតហួងហែង ។

**ទំនាយថ្ងៃវិនបត :** ថ្ងៃកណ្តាលត្រូវនឹងថ្ងៃពុធទំនាយថា : ឆ្នាំនេះ ស្រូវ អង្ករ ផ្លែឈើ មានតម្លៃខ្ពស់មនុស្សផងទាំងឡាយត្រូវក្តៅក្រហាយចិត្តជាច្រើន ។ ស្ត្រីទាំងឡាយនឹងត្រូវនិរាសព្រាត់ប្រាសពីទីកន្លែងទៅរស់នៅទីដទៃផ្សេងៗ ។

**ទំនាយថ្ងៃឡើងស័ក្តិ :** ថ្ងៃចុងក្រោយត្រូវនឹងថ្ងៃព្រហស្បតិ៍ ទំនាយថា : ឆ្នាំនេះសមណៈព្រហ្មចារ្យ និងប្រណិបត្តិចូលចិត្តដោយធមិដ៏ប្រសើរវិសេស ។

**_លក្ខណៈមនុស្សកើតឆ្នាំមមែ**

លោកអ្នកកើតឆ្នាំមមែពង្សទេវតាស្រីនាមជាសត្វពពៃធាតុមាសទទ្បាកំណើតនៅថ្ងៃអាទិត្យសិរីធ្លាក់មកពីដៃឆ្វេងរបស់ព្រះព្រហ្មមូលព្រលឹងនៅនឹងដើមបារិកជាតិ និងដើមឫស្សីលោកអ្នកកើតឆ្នាំនេះគួរស្រោចទឹកជ្រោយដីគល់នៃដើម (បារិកជាតិ) និងដើមឫស្សី ទើបនាំឱ្យកើតមានសិរីសួស្តីដល់ខ្លួន និងក្រុមគ្រួសារ ។

មនុស្សកើតឆ្នាំនេះ ជាមនុស្សមានវាសនាខ្ពស់ ជាទីត្រូវចិត្តនៃមនុស្សទូទៅ ពេលជួបទុក្ខអាសន្នមានអ្នកធំជួយគាំពារ ។ ឬកពាសុភាពរាបសា សំដីទន់ផ្អែមពីរោះ មានមិត្តភ័ក្តិច្រើនមិនថានៅទីណា ។ ប៉ុន្តែមិត្តច្រើននាំទុក្ខមកឱ្យខ្លួនធ្វើគុណមិនបានផល មិនចេះចងគំនុំគុំកួននឹងអ្នកណាឡើយ ។ ចិត្តឆេវឆាវឆាប់ខឹងតែឆាប់បាត់ មានតណ្ហាខ្លាំងស្រើបស្រាលនឹងកាមារម្មណ៍ បៀបដូចជាភ្លើងចំបើងមានស្នេហ៍ក្នុងខ្លួនជាទីត្រូវភ្នែកនៃមនុស្សភេទផ្ទុយ ។

ជាមនុស្សនិយាយតិចតែគិតច្រើនមុននឹងលូកដៃទៅចាប់ កាន់ការងារអ្វីមួយប្រើគំនិតគិតហ្មត់ចត់ល្អិតល្អន់ ។

មុខរបរដែលស័ក្តិសមជាងគេសម្រាប់មនុស្សកើតឆ្នាំមមែនេះ គឺការលក់ដូរធ្វើជំនួញជួញប្រែនឹងបានទៅជាអ្នកមានស្តុកស្តម្ភ ពីព្រោះជាមនុស្សមានការពិចារណាល្អិតល្អន់ ។

បើធ្វើការងាររដ្ឋល្អជាមធ្យមនឹងតាំងខ្លួនទៅជាអ្នកមានបាននៅពេលឈានដល់វ័យចាស់ ។

**អ្នកកើតឆ្នាំមមែពីអាយុ០៦ឆ្នាំ ដល់៨០ឆ្នាំ**

បុរសអាយុ៨,១៥,២០,២៧,៣២,៣៩,៤៤,៥១, ៥៦,៦៣,៦៨,៧៥,៨០ឆ្នាំ និងស្ត្រីអាយុ៨,១៣,២០,២៥,៣២,៣៧,៤៤,៤៩,៥៦,៦១,៦៨,៧៣,៨០ឆ្នាំ

**ទំនាយថា :** ជាឆ្នាំនាំមកនូវជោគលាភសក្ការៈគិត ប្រកបការងារអ្វីៗតែងតែបានសម្រេចដូចសេចក្តីប្រាថ្នា គ្រប់ប្រការដែលអាចចែកចេញបានដូចតទៅនេះ :

ជោគលាភ នឹងបានទ្រព្យសម្បត្តិ លុយកាក់មាស ប្រាក់ និងវត្ថុមានតម្លៃគ្រឿងប្រដាប់លម្អគេហដ្ឋាន ដីធ្លី ឬបានឡើងប្រាក់ខែ និងប្រាក់បំណាច់រង្វាន់ផ្សេងៗទៀត ។

កិត្តិយស ការសិក្សានឹងបានប្រឡងជាប់ ដូចសេចក្តី ប្រាថ្នា បើនៅទំនេរនឹងបានការងារធ្វើ បើមានការងារធ្វើស្រាប់ ហើយនឹងបានឡើងកាន់មុខតំណែងខ្ពស់ឡើង ។

កេរ្តិ៍ឈ្មោះនឹងបានទទួលសេចក្តីនិយមរាប់អាន លើកតម្កើងមុខមាត់ពីមនុស្សក្នុងមជ្ឈដ្ឋានការងារ ឬនៅ ក្នុងផ្ទះជាទីពេញចិត្តដល់ខ្លួនឯងនិងអ្នកដទៃ ។

សេចក្តីសុខនឹងបានជួបប្រទះនឹងសេចក្តីស្នេហ៍ដ៏ បរិសុទ្ធ ឯអ្នកដែលមានគូគ្រងហើយនឹងមានបុត្រជា ទីស្រលាញ់ពេញចិត្តសេចក្តីសុខនឹងកើនទ្វេឡើងថែម ទៀត ។

**បុរសអាយុ៣២,៣៩,៤៤,៥១,៥៦ឆ្នាំ**
**និងស្ត្រី៣២,៣៧,៤៤,៤៩ឆ្នាំ**

**ទំនាយថា :** បើរៀបអាពាហ៍ពិពាហ៍ ហើយនឹងមានកូនបើនៅលីវនឹងបានរួមរក្សអភិរម្យសមសេចក្តី បំណងប៉ងប្រាថ្នា ឬបានទទួលលាភសក្ការៈជាវត្ថុមាន ជីវិតផ្សេងៗទៀតចូលមកនៅផ្ទះ ។

បុរសអាយុ០៧,១៦,១៩,២៨,៣១,៤០,៤៣,៥២, ៥៥,៦៤,៦៧,៧៦,៧៩ឆ្នាំ

និងស្ត្រីអាយុ០៦,១៥,១៨,២៧,៣០,៣៩,៤២,៥១,៥៤,៦៣,៦៦,៧៥,៧៨ឆ្នាំ

**ទំនាយថា :** ជាឆ្នាំនាំមកនូវគ្រោះកាចឱ្យប្រញាប់ប្រុងប្រយ័ត្ន ខ្លួនដែលអាចចែកចេញបានតទៅនេះ :

**១-**នឹងជួបប្រទះរឿងទុក្ខសោក ខូចចិត្តដោយពពួកសត្រូវ ក្រុមពាលទាំងឡាយប៉ងព្យាបាទ កុំធ្វើដំណើរទៅទីស្ងាត់ និងពេល រាត្រី ព្រោះនឹងត្រូវចោរគំរាមកំហែង ។

**២-**រោគព្យាធិបៀតបៀនកាយ សត្វអាសិរ្ពិសទិចខាំធ្វើឱ្យ អស់សេចក្តីសុខ ។

**៣-**លុយកាក់ត្រូវចំណាយច្រើន ទាំងក្នុងផ្លូវ ដែលចាំបាច់ និងមិនចាំបាច់ដែលអាចហៅបានថា ជាឆ្នាំដែលចុះដើមទុនក្នុងផ្លូវ ដែលចាំបាច់ និងជាឆ្នាំនៃការចំណាយទៅក្នុង ផ្លូវដែលមិនចាំបាច់ បើធ្វើជំនួញជួយប្រែនឹងត្រូវខាតដើមទុន ។

**៤-**សង្ឃឹមផលប្រយោជន៏ទៅលើផ្លូវអ្វីច្រើនតែខុសភ្លាំងភ្លាត់ប្រាក់ចំណូលតិចជាងប្រាក់ចំណាយ ឬបានមកហើយចាយអស់ទៅវិញ ។

**៥-**បងប្អូនញាតិមិត្តដែលធ្លាប់ស្រឡាញ់រាប់អាននឹងប្រែក្លាយជាសត្រូវ ។

**៦-**ទីលំនៅ ឬកន្លែងធ្វើការត្រូវផ្លាស់ប្តូរ ឬធ្វើដំណើរទៅស្រុកឆ្ងាយ ឬបើលោកអ្នកមិនចាក

**តទៅទំព័រទី ១៣**



តមកពីទំព័រទី ១២

# ឆ្នាំមមែក្នុងទំនាយមហា...

ចេញទៅទេ ក៏គង់មានមនុស្សនៅក្នុងផ្ទះចាកចេញទៅដែរ ។

**៧-**រងទទួលសេចក្តីយ៉ាប់យ៉ឺន លំបាកលំបិន ឬនឿយហត់ជាខ្លាំងទាល់តែមានមានះអត់ធន់ ។

**៨-**ធ្វើការងារជាមួយអ្នកដទៃ នឹងត្រូវគេឆបោកបងប្អូនញាតិមិត្តស្និទ្ធស្នាលប្រែក្លាយទៅជាសត្រូវកន្លែងធ្លាប់នៅនឹងត្រូវក្តៅក្រហាយ ឬត្រូវគេបណ្តេញចេញចិត្តថ្លើមអន្ទះអន្ទែង ។

បុរសអាយុ០៦,១៧,១៨,២៩,៣០,៤១,៤២,៥៣,៥៤,៦៥,៦៦, ៧៧,៧៨ឆ្នាំ

និងស្រ្តីអាយុ ១០,១១,២២,២៣,៣៤,៣៥,៤៦,៤៧,៥៨,៥៩,៧១,៧២,៨២ឆ្នាំ

**ទំនាយថា :** ឆ្នាំនេះជាឆ្នាំនៃប្រក្រតីកាល គឺមិនល្អណាស់ ហើយក៏មិនអាក្រក់ណាស់ណាដែរ ការសិក្សាបានត្រឹមប្រលងជាប់មិនធ្លាក់ប្រកបការងារបានផលល្មម បើធ្វើជំនួញជួយប្រែបានត្រឹមមិនខាតដើម ។

បងប្អូនញាតិមិត្តជិតឆ្ងាយ បើឧស្សាហ៍ទៅមករាប់រកគ្នាទើបអាចផ្សារភ្ជាប់ចំណងសាមគ្គីបានល្អ ។

ការងារអ្វីៗអាស្រ័យដោយការព្យាយាម ហើយប្រើការពិនិត្យពិចារណាល្អិតល្អន់ ទើបអាចរកផលកម្រៃបាន ។

សេចក្តីស្នេហាត្រូវប្រើសេចក្តីមានះ ព្យាយាមទើបសម្រេចផល និងអាចរឹតចំណងស្នេហារវាងគ្នា និងគ្នាបានជាបង្គួរ គឺមិនល្អពេក ហើយក៏មិនអាក្រក់ពេកតែក៏មិនអាក្រក់ពេកដល់ទៅដាច់ដោចលែងលះផ្តាច់មគ្គសង្វាសគ្នាដែរ ។

បុរសអាយុ១១,១២,២៣,២៤,៣៥,៣៦,៤៧,៤៨,៥៩,៦០,៧១, ៧២ឆ្នាំ

និងស្រ្តីអាយុ១៦,១៧,២៨,២៩,៤០,៤១,៥២,៥៣,៦៤,៦៥,៧៦,៧៧ឆ្នាំ

**ទំនាយថា :** ឆ្នាំនេះអន្ទោលតាមប្រាណ គឺនៅក្នុងឆ្នាំនេះ បើលោកអ្នកធ្វើល្អនឹងបានទទួលផលល្អ បើធ្វើអាក្រក់បានអាក្រក់តបស្នងវិញ យ៉ាងប្រាកដ ។

ធ្វើការងារអ្វីៗប្រដូចទៅនឹងស្រមោលអន្ទោលតាមប្រាណខុសហើយ គឺត្រូវទទួលផលកម្មដោយគ្មានការអភ័យ ឬបន្ធូរបន្ថយគ្មានផ្លូវនឹងផ្លាស់ប្តូរកែកុនថា ធ្វើអាក្រក់ឱ្យក្លាយទៅជាល្អ ឬធ្វើល្អទៅអាក្រក់បានទេ បើទុកជាគេជួយក៏មិនរួចដែរ ។

បុរសអាយុ៩,១៤,២១,២៦,៣៣,៣៨,៤៥,៥០,៥៧,៦២,៦៩, ៧៤,៨១ឆ្នាំ

និងស្រ្តីអាយុ ៧,១៤,១៩,២៦,៣១,៣៨,៤៣,៥០,៥៥,៦២,៦៧, ៧៤,៧៩ឆ្នាំ

ទំនាយថា ឆ្នាំនេះជាឆ្នាំនៃការមានជោគលាភ ប៉ុន្តែនឹងល្អបានទៅតាមលំដាប់ គឺចាប់តាំងពីដើមឆ្នាំ ហើយនឹងចេះតែកើនឡើងៗពីតិចទៅច្រើនជាលំដាប់រហូតដល់ចុងឆ្នាំ ។ ការសិក្សានឹងចេះតែរីកចម្រើនទៅមុខបន្តិចម្តងៗ លុះដល់ចុងឆ្នាំទើបល្អពេញកម្រិត ។

ការងារអ្វីៗក៏ដូចគ្នាដែរ នៅដើមឆ្នាំមិនសូវមានការរីកចម្រើនខ្លាំងប៉ុន្មានទេ ដល់ទៅកណ្តាលឆ្នាំ ទើបឃើញផលល្អជាមធ្យម លុះចុងឆ្នាំទើបទទួលផលពេញបរិបូណ៌ ។

ភាពរីកចម្រើននឹងឃើញបានចាប់ពីខែឧសភាឡើងទៅ ហើយចេះតែកើនចម្រើនទៅជាលំដាប់រហូតពេញលេញបរិបូណ៌ដល់ទៅចុងឆ្នាំ ។

បុរសអាយុ១០,១៣,២២,២៥,៣៤,៣៧,៤៦, ៤៩,៥៨,៦១,៧០,៧៣,៨២ឆ្នាំ

និងស្រ្តីអាយុ០៩,១២,២១,២៤,៣៣,៣៦,៤៥,៤៨,៥៧,៦០,៦៩,៧២,៨១ឆ្នាំ

**ទំនាយថា :** ឆ្នាំនេះជាឆ្នាំមានគ្រោះថ្នាក់ធំ ចូរប្រុងប្រយ័ត្នឱ្យមែនទែន ព្រោះហេតុនឹងកើតឡើងបានជាច្រើនប្រការ គឺ :

**១-**កើតហាយនៈ លិចលង់ គឺត្រូវខូចខាតលុយកាក់អស់រលីងពីខ្លួន ។

**២-**កើតការផ្លាស់ប្តូរ ព្រាត់ប្រាសនិរាសចាកចោលគ្នា ដោយសត្រូវធ្វើទោស ឬជួបសេចក្តីទុក្ខលំបាក ឬត្រូវធ្វើដំណើរទៅស្រុកឆ្ងាយដោយមានហេតុចាំបាច់ ។ ចំពោះអ្នកដែលមានបំណងនឹងផ្លាស់ប្តូរ ឬចង់ធ្វើដំណើររមែងបានដូចសេចក្តីបំណង ។

**៣-**បងប្អូនញាតិមិត្តជាទីស្រលាញ់នឹងប្រែក្លាយទៅជាសត្រូវស្អប់ខ្ពើមគ្នា ។

**៤-**ត្រូវគេឆបោកកេងប្រវ័ញ្ចធ្វើបាបឱ្យខូចខាតនូវរបស់ជាទីស្រលាញ់ហួងហែងជាទីគាប់ចិត្ត ។

**៥-**ត្រូវចោរលួច ឬភ្លើងឆេះឱ្យបានទទួលសេចក្តីក្តៅក្រហាយនឹងការខកចិត្ត ។

**៦-**អ្នកធ្វើការជាមួយគ្នា មានគំនិតផ្តន្ទាឈ្នានីស ឬរង់ចាំចាប់កំហុស ជាហេតុធ្វើឱ្យទទួលទោសទណ្ឌ ធ្វើការងារច្រើនលើសលន់ ប៉ុន្តែសេចក្តីគួរគាប់គ្មានត្រូវគេបោកបញ្ឆោតទៅក្នុងផ្លូវអកុសល ។

## ថ្ងៃជាសិរីមង្គល

ថ្ងៃដែលជាសិរីមង្គល ដើម្បីជ្រើសរើសសម្រាប់ប្រើក្នុងពិធីសំខាន់ៗរបស់ខ្លួនដូចជារៀបអាពាហ៍ពិពាហ៍ លើករាសីបុណ្យទានធំៗពិធីជាមង្គលផ្សេងៗដែលទាក់ទងនឹងសុវត្ថិភាពសេចក្តីចម្រុងចម្រើនរុងរឿងក្នុងជីវិតត្រូវតែចាប់ផ្តើមឡើងដំបូងគឺថ្ងៃ :

១-ថ្ងៃអាទិត្យ ២-ថ្ងៃចន្ទ ៣-ថ្ងៃពុធ ៤-ថ្ងៃព្រហស្បតិ៍

បើប្រុសគួរជ្រើសរើសគូស្រករដែលមានឆ្នាំកំណើត ឆ្នាំថោះ ឆ្នាំវក

បើប្រុសមិនគួរជ្រើសរើសគូស្រករដែលមានឆ្នាំកំណើត ឆ្នាំម្សាញ់ ឆ្នាំឆ្លូវ ឆ្នាំមមែ និងកុរ

បើស្រីគួរជ្រើសរើសគូស្រករដែលមានឆ្នាំកំណើតឆ្នាំថោះ ឆ្នាំកុរ និងឆ្នាំរោង

បើស្រីមិនគួរជ្រើសរើស

គូស្រករដែលមានឆ្នាំកំណើត ឆ្នាំខាល ឆ្នាំមមែ និងឆ្នាំច ៕


# GATEWAY FAMILY DENTAL

www.gatewayfamilydental.com • (978) 455-5044

151 WARREN STREET, SUITE 120 LOWELL, MA 01852 (Same building as Social Security/near the courthouse)



**DR. SERENA B. CHUOP**

Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 13 years, she has been in private practices providing all aspects of General Dentistry. Her state of the art dental practice includes digital x-rays, paperless patient chart system, and new dental equipments.




**WE PROVIDE ALL SERVICES INCLUDING: យើងផ្តល់នូវសេវាដូចខាងក្រោមនេះ**

- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS

- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN

- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជុំនួសធ្មេញដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមរន្ធធ្មេញចាស់

- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វ៉េរនីស្រោបធ្មេញ
- ព្យាបាល និងការពារធ្មេញជាទៀងទាត់
- ព្យាបាល ឫសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

Free Teeth Whitening Kit
(with new patient´s x-ray, exam, cleaning at regular price)

MOST DENTAL INSURANCES ACCEPTED
INCLUDING MASSHEALTH
FINANCING AVALIABLE
យើងទទួលនូវគ្រប់ អ៊ិន ស៊ូរិន
Masshealth
យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ
CALL FOR YOUR FREE CONSULTATION
(978) 455-5044

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសំរួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# សកម្មជនដីធ្លីត្រូវបានដោះលែង បន្ទាប់ពីកំណែទម្រង់ការបោះឆ្នោតបានបញ្ចប់

ដោយៈ ម៉ិច ដារ៉ា | April 13, 2015

សកម្មជនសិទ្ធិដីធ្លីដែលជាប់ពន្ធនាគារចំនួន១០នាក់ បានអបអរសាទរនៅភូមិគ្រឹះរបស់លោក កឹម សុខា អនុប្រធានគណបក្សសង្គ្រោះជាតិ នៅក្នុងរាជធានីភ្នំពេញកាលពីរសៀលថ្ងៃសៅរ៍ បន្ទាប់ពីត្រូវបានដោះលែងពីពន្ធនាគារក្រោយពេល ការចរចាផ្នែកនយោបាយរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិត្រូវបានបញ្ចប់។

សកម្មជនសិទ្ធិដីធ្លីដែលមកពីសហគមន៍បឹងកក់ក្នុងរាជធានីភ្នំពេញទាំងនេះ ត្រូវបានចាប់ខ្លួន ហើយត្រូវបានផ្តន្ទាទោសយ៉ាងឆាប់រហ័សឱ្យជាប់ពន្ធនាគារក្នុងម្នាក់ៗរយៈពេល១ឆ្នាំកាលពីខែវិច្ឆិកា ក្រោយពេលការតវ៉ាមួយដែល ស្រ្តីចំនួនប្រាំពីរនាក់ក្នុងចំណោមស្រ្តីទាំងនេះបានយកគ្រោងគ្រែបិទផ្លូវអំឡុងពេលនោះ។

លោក សម រង្ស៊ី មេដឹកនាំគណបក្សប្រឆាំងបានអះអាងម្តងហើយម្តងទៀតថា ការចាប់ខ្លួនស្ត្រីទាំងនេះព្រមទាំងការចាប់ខ្លួនអតីតព្រះសង្ឃ និងមន្រ្តីគណបក្សសង្គ្រោះជាតិចំនួនប្រាំបីនាក់ផ្សេងទៀតផងនោះ គឺត្រូវបានធ្វើឡើងក្នុងគោលបំណងជំរុញឱ្យគណបក្សសង្គ្រោះជាតិដកការទាមទាររបស់ខ្លួននៅក្នុងការចរចាស្តីពីកំណែទម្រង់ការបោះឆ្នោត។

ការអះអាងដូច្នេះត្រូវបានបដិសេធជាសាធារណៈដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលលើកឡើងថា លោកគ្មានអំណាចទៅ ជ្រៀតជ្រែកក្នុងប្រព័ន្ធតុលាការនោះ។ តែទោះជាយ៉ាងណា ការដោះលែងសកម្មជនសិទ្ធិដីធ្លីទាំង១០នាក់នេះកាលពីថ្ងៃសៅរ៍ គឺត្រូវបានធ្វើឡើងត្រឹមតែពីរថ្ងៃប៉ុណ្ណោះបន្ទាប់ពីរដ្ឋសភាបានសម្រេចជាចុងក្រោយនូវកិច្ចពិភាក្សារបស់ខ្លួនក្នុងការអនុម័តកំណែ ទម្រង់ការបោះឆ្នោត ដែលបានពិភាក្សាគ្នា

តទៅទំព័រទី ២២

## With Election Talks Over, Jailed Activists Freed

By MechDara | April 13, 2015

Ten imprisoned land-rights activists celebrated at CNRP Vice President KemSokha's villa in Phnom Penh on Saturday afternoon after being released from jail following the end of political negotiations between the CPP and CNRP.

The activists, from Phnom Penh's BoengKak community, were arrested and swiftly given yearlong prison sentences in November following a protest during which seven of the group blocked a road with a bed.

Land-rights activist NgetKhun greets relatives in Phnom Penh's BoengKak neighborhood after being released from prison on Saturday. (John Vink)

Opposition leader Sam Rainsy has repeatedly claimed that the arrests-along with those of eight separate CNRP officials and monks-were intended to push CNRP negotiators to back down in election-reform talks.

The claims were publicly denied by Prime Minister Hun Sen, who insisted that he did not have the power to interfere with the court system. However, the release of the 10 activists on Saturday came only two days after the parliament finalized its tasks in passing the negotiated electoral reforms.

Emerging from Phnom Penh's Prey Sar prison shortly after 3:30 p.m. on Saturday, the housing rights activists-TepVanny, NgetKhun, Song Sreyleap, Kong Chantha, Pan Chunreth, Bop Chorvy, NongSreng, HengPich, ImSrey Touch and PuongSopheap-were embraced by about 100 of their relatives, community members and CNRP officials.

"The 10 of us are very happy to rejoin our families, especially our children, communities and organizations," Ms. Vanny said Saturday. "We are innocent people and we suffered an injustice from the non-independent courts in Cambodia, which arrested and put us in prison for five months."

Speaking by telephone Sunday, Ms. Vanny said the sequence of events since the CPP and CNRP ended their eight months of contentious negotiations on electoral reform on Thursday made clear that her arrest was political in nature.

"The Cambodian government is weak and cheap, as [Mr. Hun Sen] has no capability or power to compete with his

Continued to Page 23

# ក្រោយពីរយៈពេល៩ខែ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មីបង្កើតនៅថ្ងៃនេះ

ដោយៈ ហ៊ុល រស្មី | APRIL 13, 2015

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មី (K.C.b.) ជាសសរគ្រឹះសំខាន់មួយនៃកិច្ចព្រមព្រៀងនយោបាយកាលពីឆ្នាំមុន រវាងគណបក្សប្រជាជនកម្ពុជានិងគណបក្សសង្គ្រោះជាតិ នឹងបន្តភារកិច្ចរបស់ខ្លួនជាផ្លូវការ ជាស្ថាប័នរៀបចំការបោះឆ្នោតរបស់ប្រទេសកម្ពុជានៅខែនេះ បន្ទាប់ពីរយៈពេលជិត៩ខែនៃការចរចានិងការរៀបចំ។

សន្យាជាផ្នែកមួយនៃកិច្ចព្រមព្រៀងដែលបានបញ្ចប់ការធ្វើពហិការមិនចូលសភារយៈពេល១០ខែរបស់គណបក្សសង្គ្រោះជាតិ ទាក់ទិននឹងការតវ៉ារបស់ខ្លួន ថាការបោះឆ្នោតឆ្នាំ២០១៣ មានការលួចបន្លំនោះ គណបក្សទាំងពីរបានប្រកាសឱ្យដឹងថា ស្ថាប័នថ្មីនេះជាដំណោះស្រាយមួយចំពោះរាល់ជម្លោះក្រោយការបោះឆ្នោតណាមួយនៅពេលអនាគត។

សមាជិក៩រូបនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មី ដែលជ្រើសរើសដោយគណបក្សទាំងពីរ ត្រូវបានសភាអនុម័តយល់ព្រមកាលពីសប្តាហ៍មុន និងបានស្បថចូលកាន់មុខតំណែងកាលពីថ្ងៃសៅរ៍ មុនពិធីនៅព្រឹកនេះ ដើម្បីទទួលការផ្ទេរអំណាចពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចាស់។

លោក ស៊ិក ប៊ុនហុក ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មី ដែលបានជួយព្រាងច្បាប់បោះឆ្នោតថ្មីនេះ និងជាតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានមានប្រសាសន៍ថា "នេះជាអំណោយមួយពីថ្នាក់ដឹកនាំជាតិ។ យើងនឹងខិតខំធ្វើអ្វីគ្រប់យ៉ាងដែលយើងអាចធ្វើបានដើម្បីប្រើអំណោយនេះដូចដែលថ្នាក់ដឹកនាំចង់បាន"។

លោក រ៉ុង ឈុន មេដឹកនាំសហជីពដែលត្រូវបានជ្រើសដោយគណបក្សសង្គ្រោះជាតិ ជាសមាជិកមួយរូបនៃសមាជិក៩រូបរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មី បានមានប្រសាសន៍ថា លោករីករាយដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មីអាចបង្កើតឡើងមុនថ្ងៃឈប់សម្រាក។

លោក ឈុន បានមានប្រសាសន៍ថា "ការផ្ទេរ តំណែងនេះគឺដោយជួនពេល ព្រោះថ្ងៃស្អែកជាថ្ងៃមួយមុនចូលឆ្នាំខ្មែរ សមាជិកចាស់ៗនឹងចេញ ហើយសមាជិកថ្មីនឹងចូលកាន់តំណែង"។

លោក ឈុន ដែលឥឡូវត្រូវមានភាពអព្យាក្រិតផ្នែកនយោបាយក្នុងនាមជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបន្ថែមថា "យើងសង្ឃឹមថា នឹងមានការផ្ទេរតំណែងថ្នាក់ដឹកនាំ បន្ទាប់ពីការបោះឆ្នោតពីរលើកនៅឆ្នាំ២០១៧និងឆ្នាំ២០១៨"៕ និត

## After Nine Months, New National Election Committee Forms Today

BY HUL REAKSMEY | APRIL 13, 2015

The new National Election Committee (NEC), a key pillar of last year's political deal between the CPP and the CNRP, will formally assume its duties as the country's election-organizing body this morning after almost nine months of negotiations and preparations.

Promised as part of the deal that ended the CNRP's 10-month boycott of the National Assembly over its complaints that the 2013 election was rigged, both parties have advertised the new institution as a solution to any future post-election disputes.

The nine members of the new NEC, selected by both parties, were approved by parliament last week and were sworn into their positions on Saturday ahead of a ceremony this morning to transfer power from the old NEC.

"This is a gift from the leaders to the nation," said incoming NEC Chairman Sik Bunhok, who helped draft the new election laws as a CPP lawmaker. "We will do whatever we can to use this gift as the leaders want."

Rong Chhun, a union leader who was selected by the CNRP as one of the new NEC's nine commissioners, said he was glad the new NEC could form before the holiday.

"This transfer of positions is fortuitous, as tomorrow is one day before Khmer New Year and the old members are going out and the new members are coming in," Mr. Chhun said.

"We hope there will be a leadership transfer after the two elections in 2017 and 2018," added Mr. Chhun, who must now uphold political neutrality as an NEC member.

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# មិនដល់មួយឆ្នាំផងបន្ទាប់ពីបើកដំណើរការ ហាងមួយចំនួននៅផ្សារទំនើបអ៊ីអនបានបិទទ្វារ

ដោយ កង សុធា និង ANTHONY JENSEN | APRIL 23, 2015

មិនដល់១០ខែផង បន្ទាប់ពីផ្សារទំនើបអ៊ីអន ដែលចំណាយអស់ទឹកប្រាក់២០០លាន-ដុល្លារបានបើកទ្វារសម្រាប់អតិថិជនក្នុងរាជធានីភ្នំពេញ មានហាងយ៉ាងតិចចំនួនប្រាំពីរនៅក្នុងផ្សារទំនើបដ៏ធំបំផុតនៅកម្ពុជានេះបានបិទអាជីវកម្មរបស់ខ្លួនដោយពួកគេលើកឡើងពីមូលហេតុថា មានតែមនុស្សច្រើន ប៉ុន្តែពុំសូវមានអ្នកទិញ និងដោយសារតែការរំខានពីការសាងសង់នៅផ្សារនេះ។

ខណៈផ្សារទំនើបអ៊ីអនបដិសេធមិនផ្តល់តួលេខពិតប្រាកដសម្រាប់ចំនួននៃហាង ភោជនីយដ្ឋាន និងហាងកាហ្វេ ដែលដើរចេញពីផ្សារគ្រប់គ្រងដោយជប៉ុននេះ ការសម្ភាសមួយចំនួននៅក្នុងខែនេះបានបង្ហាញថា មានហាងយ៉ាងតិចប្រាំពីរបានបិទទ្វារ ក្នុងនោះមានហាងចំនួនប្រាំមួយបានបិទទ្វារចាប់តាំងពីដើមខែកុម្ភៈមកម្ល៉េះ។

ហាងទាំងនោះរួមមានដូចជាហាង Fox Wine Bistro គ្រប់គ្រងដោយក្រុមហ៊ុនតែមួយដែលបើកហាង Brown Cafe នៅក្នុងស្រុក និងហាង Miam Miam ជាភោជនីយដ្ឋានសិង្ហបុរីដែលចាប់ដៃគូរជាមួយក្រុមហ៊ុនក្នុងស្រុក CBM ។ ហាងដែលបិទទ្វារផ្សេងៗទៀតគឺហាង Ya Kun Kaya Toast របស់សិង្ហបុរី ភោជនីយដ្ឋានជប៉ុន Kushiage Kushisho ហាងជប៉ុន Pao Pao ហាងសម្លៀកបំពាក់ក្នុងស្រុក Espada និងហាង Amadana ជាហាងរបស់ជប៉ុនដែលលក់ឧបករណ៍អេឡិចត្រូនិកទំនើបៗ។

ហើយហាងនំប៉័ងរបស់បារាំងដែលទិញសិទ្ធិពីហាងឈ្មោះ Eric Kayser និងដែលមានទីតាំង



សញ្ញាបិទផ្លូវចូលហាង ហ្វក់ វ៉ាញ បិស្ត្រូ នៅ ឯអ៊ីអន។
Ottavia Fabbri/The Cambodia daily

នៅខាងក្រៅអគារផ្សារទំនើបអ៊ីអន ក៏គ្រោងនឹងបិទទ្វាររបស់ខ្លួននៅដំណាច់ខែនេះដែរ ប៉ុន្តែនៅរក្សាហាងនំប៉័ងដ៏តូចមួយក្នុងអគារ។

ដោយមានទីតាំងនៅលើដីទំហំ១០០.០០០ម៉ែត្រក្រឡាស្ថិតនៅតាមបណ្តោយមហាវិថីសុធារសក្នុងខណ្ឌចំការមន ផ្សារទំនើបដែលមានកម្ពស់៤ជាន់នេះ ត្រូវបានសម្ពោធកាលពីខែមិថុនា នៅក្នុងពិធីមួយក្រោមអធិបតីភាពរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងលោក Fumio Kishida រដ្ឋមន្ត្រីក្រសួងការបរទេស

តទៅទំព័រទី ១៧

# Amid Slow Sales, Some Aeon Tenants Leave Mall

BY ANTHONY JENSEN AND KANG SOTHEAR | APRIL 23, 2015

Less than 10 months after the $200-million Aeon Mall opened its doors to Phnom Penh's consumers, at least seven tenants at Cambodia's largest shopping center have shuttered their businesses, complaining of disappointing foot traffic, construction disturbances and overly thrifty patrons.

While Aeon declined to provide an exact figure for the number of shops, restaurants and cafes that have left the Japanese-operated retail complex, interviews this month revealed that at least seven have closed down—six of them since the start of February.

A sign blocks the former entrance of Fox Wine Bistro at Aeon Mall last week. (Ottavia Fabbri/The Cambodia Daily)

The businesses include Fox Wine Bistro, owned by the same group as local chain Brown Coffee, and Miam Miam, a Singaporean restaurant chain opened in partnership with local restaurant group CBM Corporation. The others are Singaporean chain Ya Kun Kaya Toast, Japanese restaurant Kushiage Kushisho, Japanese bun shop Pao Pao, local clothing retailer Espada, and Amadana, a Japanese store that sold high-end electronic appliances.

And French bakery chain Eric Kayser plans to shutter its restaurant on Aeon's open-air "Terrace Avenue" at the end of this month, while keeping its smaller bakery outlet inside the building.

Located on 100,000 square meters of prime land off Sothearos Boulevard in Chamkar Mon district, the four-story mall was inaugurated in June in a ceremony presided over by Prime Minister Hun Sen and Japanese Foreign Minister Fumio Kishida. With 190 shops, a seven-screen movie theater, an ice rink, a television studio and a food court, the mall offered amenities that could not be found at the city's other retail centers and was heralded as a major step in the expansion of Cambodia's consumer-oriented economy.

"This area is the one that shows the potential for other developments in Cambodia," Mr. Hun Sen said at the time.

But despite the 12 million people Aeon claims have come through the mall's doors since its opening, tenants interviewed this month identified a range of issues contributing to sales woes that ultimately proved too burdensome.

Chang Bunleang, managing partner of Fox's ownership group, said that despite the large number of people flocking to the shopping center each day, relatively few were patronizing its restaurants, explaining that

Continued to Page 17

តមកពីទំព័រទី ០៩

# ដំណើរទស្សនកិច្ចលោក អាឡិចស៊ី...

កក់ក្តៅនេះ ធ្វើឱ្យគាត់មានកម្លាំងចិត្តកាន់តែមុះមុត ក្នុងការបន្តតស៊ូ ដើម្បីសង្គ្រោះ ថែរក្សា និងការពារសម្បត្តិធម្មជាតិចុងក្រោយរបស់ខ្មែរ។

ក្នុងឱកាសនោះដែរ លោកអភិបាលក្រុងឡូវែល រ៉ត់នី អ៊ីលៀត បានចូលរួមទទួលស្វាគមន៍លោក អាឡិចស៊ី យ៉ាងកក់ក្តៅ។ មិនតែប៉ុណ្ណោះលោកគឺជាមនុស្សដំបូងគេ ដែលបានចុះហត្ថលេខាលើញត្តិ ដើម្បីអន្តរគមន៍ឱ្យលោក អាឡិចស៊ី ឱ្យបានវិលត្រឡប់ទៅស្រុកខ្មែរវិញ។ អ្នកចូលរួមប្រមាណ ៤០០ រយនាក់ ក្នុងពិធីថ្ងៃនោះ បាននាំគ្នាចុះហត្ថលេខាគាំទ្រញត្តិនោះផងដែរ។ លោកវេជ្ជបណ្ឌិត ឆាន ទូច គឺជាអ្នកផ្តួចផ្តើមសរសេរញត្តិនេះ។

លោក អាឡិចស៊ី បានបន្តធ្វើទស្សនកិច្ចនៅបណ្តារដ្ឋផ្សេងៗទៀត នៅលើទឹកដីអាមេរិក។ គ្រប់រដ្ឋដែលគាត់បានទៅដល់បងប្អូនខ្មែរ-អាមេរិកដែលស្រលាញ់ និងគាំទ្របេសកម្មរបស់គាត់ បាននាំគ្នាចេញមកទទួលស្វាគមន៍គាត់យ៉ាងច្រើនកុះករ។

ទោះជាយ៉ាងនេះក្តី មានបងប្អូនខ្មែរ-អាមេរិកខ្លះ ចាត់ទុកការគាំទ្រលោក អាឡិចស៊ី ថាជាការខ្វះការពិចារណា និង ខ្វះការឱ្យតម្លៃដល់ជាតិសាសន៍ខ្មែរខ្លួនឯង។អ្នកទាំងនោះ ថែមទាំងចោទប្រកាន់លោក អាឡិចស៊ី ថាបានមើលងាយរដ្ឋធម្មនុញ្ញខ្មែរ។ ពួកគាត់យល់ស្របតាមសម្តីលោក ហ៊ុន សែន ដែលថាគ្មានបរទេសណាស្រលាញ់ខ្មែរជាងខ្មែរខ្លួនឯងទេ។ ប៉ុន្តែបងប្អូនខ្មែរ-អាមេរិកមួយចំនួនធំ មិនយល់ស្របដូច្នេះទេ។ ពួកគាត់ចាត់ទុកជនបរទេសដូចជាលោក អាឡិចស៊ី ថាជាមនុស្សមានតម្លៃសម្រាប់ខ្មែរ។ អ្នកខ្លះហ៊ានទាំងហៅលោក អាឡិចស៊ីថាជាវីរៈបុរសថែមទៀតផង។ពួកគាត់អះអាងថា ការផ្តល់តម្លៃ និងគោរពជនបរទេសដូចជាអាឡិចស៊ី មិនមែនជាការស្អប់ជាតិសាសន៍ខ្មែរឯងនោះទេ។ ការគាំទ្រអាឡិចស៊ី មិនមែនបានន័យថា យើងមើលងាយជាតិសាសន៍ខ្មែរនោះទេ។ ជនបរទេសណា ដែលស្រលាញ់ខ្មែរដោយស្មោះត្រង់ ជននោះគួរទទួលបានការកោតសរសើរ គាំទ្រ និង គោរព។ ផ្ទុយទៅវិញ ជនបរទេសណាដែលកេញប្រវ័ញ្ចញើសឈាមខ្មែរ បំផ្លាញធនធានធម្មជាតិខ្មែរ ធ្វើឱ្យខ្មែរបែកបាក់ ឬ រងទុកខ្លោចផ្សា ជនបរទេសនោះមិនគប្បីទទួលបានការស្វាគមន៍ និង គោរពនោះទេ។ អ្នកខ្លះថែមទាំងផ្ទាញ់សម្តីលោក ហ៊ុន សែន និងអ្នកដែលអួតថាស្រលាញ់ខ្មែរជាងជនបរទេសចុះហេតុដូចម្តេចបានជាគាត់អនុញ្ញាតឱ្យគេធ្វើបាបរាស្ត្រខ្មែរឱ្យរស់រងទុក្ខវេទនា ដីធ្លីត្រូវគេរឹបអូសត្រូវគេបណ្តេញចេញពីផ្ទះ ចាប់ដាក់គុកច្រវ៉ាក់បាញ់សម្លាប់ដោយសារតវ៉ាសុំតម្លើងប្រាក់ខែ ។ល។ និង ។ល។?

ពលរដ្ឋខ្មែរភាគច្រើនក្នុងសហគមន៍ សម្តែងមតិចង់ឱ្យមានជនជាតិខ្មែរ និងជនបរទេសដូចអាឡិចស៊ីឱ្យកាន់តែច្រើនជាងនេះ ដើម្បីនាំគ្នាក្រោកឡើងការពារសម្បត្តិធម្មជាតិចុងក្រោយរបស់ខ្មែរ។ ពួកគាត់ យល់ថា លោក ហ៊ុន សែន គ្មានសមត្ថភាពការពារធនធានធម្មជាតិខ្មែរទេ។ សូម្បីតែលោក ហ៊ុន សែន និយាយពេញមាត់ថា ព្រៃឈើខ្មែរហិនហោចអស់ហើយពីមុនគេហៅព្រៃវែង ដោយសារខេត្តនេះមានព្រៃក្រាស់ និងវែងប៉ុន្តែក្នុងសម័យនេះ ព្រៃវែងក្លាយជាវាលវែង

តទៅទំព័រទី ១៦

## តមកពីទំព័រទី ០៧ ទឹករងថ្លាទើបឃើញ...

**កាន់អំណាចជារដ្ឋាភិបាលស្របច្បាប់"** ។ប្រឈមមុខនឹងប្រជាពលរដ្ឋបះបោររាប់ខែយ៉ាងគគ្រឹកគគ្រេង រកកល្បនឹងដួលរលំ គណបក្សប្រជាជនបានឃើញខ្លួនឯង បាត់បង់មូលដ្ឋានគាំទ្រថា ជា **"អ្នកឈ្នះឆ្នោត"** នោះអស់រលីងនៅសល់តែកម្លាំងកងទ័ព នឹងប៉ូលីស ខ្លះតែប៉ុណ្ណោះ។ ត្រៀមប្រើកម្លាំងប្រដាប់អាវុធ គណបក្សប្រជាជនដំណាងដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រថុយប្រឋានជាទឹកចុងក្រោយ... ស្រាប់តែគណបក្សសង្គ្រោះជាតិ បញ្ឈប់មហាបាតុកម្មរបស់ខ្លួនដាច់ត្រឹមតាំងពីចុងខែធ្នូ២០១៣ រហូតមក ល់ថ្ងៃនេះហើយបញ្ចេញយុទ្ធសាស្ត្រថ្មីមួយទៀតដែលមហាជនគិតមិនដល់ ឬក៏បានពន្យល់ដោយ-មានការលាក់លៀម ។ការសម្រេចចូលសភាទទួលតំណែងរបស់គណបក្សសង្គ្រោះជាតិ ដោយមានលក្ខខណ្ឌ បានន័យថា ជាការទទួលស្គាល់ **"អ្នកកាន់អំណាចជារដ្ឋាភិបាលស្របច្បាប់"** ដូច្នេះលទ្ធផលនៃការបោះឆ្នោត២០១៣ ក៏ **"ទទួលយកបាន"** ទៅវិញ ដែលជាហេតុធ្វើឱ្យដៃគូរតស៊ូបាតុកម្មអហឹង្សា មិនយល់ ហើយអាក់អន់ចិត្តយ៉ាងខ្លាំង ខ្លះថាជា **"អំពើក្បត់"** តែនៅបន្ត តស៊ូធ្វើបាតុកម្ម ក្នុងបុព្វហេតុ**"សង្គម"**ម្នាក់ឯង មិនឈប់ឈរដដែល... នេះជាការ**"តស៊ូក្រៅអំណាច"** តែគ្មានគណបក្សសង្គ្រោះជាតិទន្ទឹមគ្នា ទៀតទេ។

**វគ្គទី២**-នៅពេលសម្រេចចូលទទួលដំណែងជាសមាជិកសភាជាតិ របស់គណបក្សសង្គ្រោះជាតិ្ប បាតុកម្មពលរដ្ឋមិនបានត្រូវបញ្ចប់នៅឡើយ, ការចាប់ចងវាយបង្ក្រាប ដាក់ពន្ធនាគារមានប្រើហឹង្សានានា ដោយរដ្ឋអំណាចរបស់គណបក្សប្រជាជនដើម្បីបុព្វហេតុនយោបាយនៅតែមាន,ហើយនឹងនៅមានការចរចាយ៉ាងតឹងសសៃករវាងគណបក្សប្រជាជនកម្ពុជា នឹងគណបក្សសង្គ្រោះជាតិមួយទៀត្ស ដើម្បីគោលដៅធំតែមួយគត់ គឺបង្កើតគ.ជ.ប. ឯករាជ្យមួយឱ្យបាន។ ការបន្តកូរទឹកឱ្យល្អក់ នៅតែមានដដែល...ក៏ប៉ុន្តែក្នុងដំណើរជាគណបក្សប្រឆាំងស្របច្បាប់គណបក្សសង្គ្រោះជាតិ បានផ្តល់គំរូថ្មីនៃសភាអនាគតគឺមានការដេញដោលពីសកម្មភាពរដ្ឋាភិបាល-មានការចរចាព្រមព្រាងកែប្រែច្បាប់ ពីគណបក្សលើសពី១- មានការចេញទៅជួបជួយដោះស្រាយវិបត្តិធំៗរបស់ប្រជាពលរដ្ឋ-ដាក់សម្ពាតឱ្យរដ្ឋាភិបាលដាក់ទណ្ឌកម្មដល់មន្ត្រីខិលខូច-ដាក់សម្ពាតឱ្យគ្រប់គ្រងអន្តោប្រវេសន៍ចូលមកកម្ពុជា... ។ល។ តែក៏មានអ្នកដែលយល់ថា **"ទង្វើខាងលើតែ១អាចមានន័យ២"**: គឺ១-ជាការលក់ខ្លួនឱ្យរដ្ឋាភិបាលគណបក្សប្រជាជនពីព្រោះទៅ**"ជួយឱ្យសភានឹងរដ្ឋាភិបាលទៅជាស្របច្បាប់"** - ចំណែកឯទី២ គណបក្សសង្គ្រោះជាតិ ទំនងជាយល់ថា ខ្លួនមានភារកិច្ចត្រូវជម្រុញឱ្យមន្ត្រីរបស់ខ្លួនមាន**"បទពិសោធន៍នឹងកិត្តិយស"**ជាបុគ្គលិកនិតិប្រតិបត្តិឱ្យហើយ សម្រាប់ទៅកាន់ជំនួសអំណាចនាឱកាសឈ្នះឆ្នោតខាងមុខដែរ ដូច្នេះសមាជិកសភាត្រូវតែចេះដើរតួរឱ្យខ្ពស់ជាងរដ្ឋាភិបាលដែលខ្លួនដាក់បញ្ហាឱ្យកាងារធ្វើ ហើយតាមដានការអនុវត្តបញ្ហានោះ រហូតដល់ចប់ ទោះជាសមាជិករដ្ឋាភិបាលនោះចង់ឬមិនចង់ក្តី...ចំណែកឯសមាជិកសភាគណបក្សប្រជាជន ពុំដែលបានធ្វើកាងាររបៀបនេះទេ ពីព្រោះលោក ហ៊ុន សែន បានធ្វើកិច្ចការទាំងនោះជំនួសអស់ទៅហើយ។

ឥឡូវគ.ជ.ប.បង្កើតថ្មីបានហើយ តើអ្វីៗនឹងត្រូវបញ្ចប់ ឬក៏នឹងមានអ្វីទៀតកើតឡើង? លោក ហ៊ុន សែន ដឹកលោក សម រង្ស៊ី នាំដើរត្រួតពលរដ្ឋរួមគ្នា ហើយប្រកាសមិត្តភាពយូរអង្វែង នៅសៀមរាប- អ្នកទោសនយោបាយទាំងអស់ បានត្រូវដោះលែងពីគុកព្រៃសរ... ទឹករលកបានក្រាបមែន នៅពេលស្ងប់ខ្យល់ ក៏ប៉ុន្តែទឹកល្អក់ពុំបានរងថ្លាមកវិញនៅឡើយផងទេ ពីព្រោះជាថ្មីម្តងទៀត ទង្វើ១មានន័យ២ដដែល មិនអាចជឿទាំងស្រុងបានទេ ទី១-គឺលោក ហ៊ុន សែន នៅក្តាប់ស្ថានភាពនយោបាយទាំងស្រុង

តទៅទំព័រទី ៣១




## តមកពីទំព័រទី ១៩ ដំណើរទស្សនកិច្ចលោក អាឡិចស៍...



ហើយ (sic!) ព្រោះ អស់ព្រៃ។ លោក ហ៊ុន សែន ធ្លាប់សន្យាជាឱឡារិក ថាបើគាត់ទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ មិនបានគាត់ហ៊ានកាត់ក្បាលគាត់ចោល។ ក្រោយការសន្យារបស់គាត់ ការកាប់បំផ្លាញព្រៃ ឈើនៅតែបន្តគ្មានស្រាកស្រាន្ត។

អាឡិចស៍ចេញពីឡូវែលទៅ ដោយនាំទាំងថវិកា៧ពាន់ដុល្លា ពីសហគមន៍ខ្មែរឡូវែលទៅជួយគាំទ្រសកម្មជនមាតាធម្មជាតិ ឱ្យបន្តការទប់ស្កាត់រដ្ឋអំណាច នឹងឈ្មួញកុំឱ្យឈប់បំផ្លាញព្រៃឈើតទៅទៀត៕

## តមកពីទំព័រទី ០៦ ខ្មែរដំបូងគេដែលបានកសាងផ្សារប៉ៃលិន...

មានអ្នកចូលហ៊ុន៤, ៥នាក់ទៀត កាងារក៏សម្បូរអេឡិកត្រូនិក ក៏ដើរ គ្រាន់តែមកដល់ឆ្នាំ១៩៩០ ខ្មែរឡើងដល់២ម៉ឺននាក់...ស្តូរពេលនោះមាន១១ ចំណែកស្តូរខ្ញុំ ជាស្តូរទី៣។ ពេលខ្ញុំបើកស្តូរនោះកន្លែងម្តុំនេះគ្មានអ្វីទាំងអស់ គេហៅទីនេះថា Ghosh town ហ្គោសថោន គឺក្រុងខ្មោច... នៅជាប់នេះ ពីដើមជាហាងសាំង ម៉ាលី ថៃឆ្នាំ៩១ នឹង ៩២នោះមានក្មេងច្រើនក្រុមណាស់ ជាសម្បុករបស់ពួកក្មេង ក្រុមកូនខ្មែរក៏មានដែរ ខ្ញុំខ្លាចដែរ តែមិនហ៊ានបង្ហាញឱ្យដឹងទេ កុំឱ្យវាមកដាក់ខែខ្ញុំមិនឱ្យទេ! មកម្តងៗឱ្យអីខ្លះទៅ ពេលខ្លះខ្លាចពេក ក៏ហៅប៉ូលីសឱ្យជូនទៅផ្ទះ ... បើកបាន១ឆ្នាំភ្លើងឆេះអស់

**ខ្មែរផុស:** ដូច្នេះហាងត្រូវបិត ឬត្រូវបន្តយ៉ាងដូចម្តេច?

**ឡាច ប៊ុនរិទ្ធ:** ឡាចយើងមានអិនស្សូរិន តែមិនចាំអិនស្សូរិនសងនោះទេ មិត្តភក្រ្តគេឱ្យខ្ចីម្នាក់៤, ៥ម៉ឺន ក៏អាចធ្វើហាងបានឡើងវិញ ហើយតមេឡឹងបានជា២ជាន់ថែមទៀត យ៉ាងឆាប់រហ័សដល់អិនស្សូរិនសងមក ទើបយកទៅសងគេវិញ

**ខ្មែរផុស:** តើមានមិត្តភក្រ្តណាខ្លះដែលមានស្នាដៃ ជួយជ្រោមជ្រែង ឱ្យផ្សារពាណិជ្ជកម្មលេចចេញមកបាន?



ប៊ុនរិទ្ធ: ឡាចមានលោក វ៉ាន់ ថន លោក សារឿន លោក ជា តែម លោក សម្បត្តិ ... បានជួយឱ្យពង្រីកធំបាន បានពីរបីឆ្នាំ យើងមានគម្រោងធ្វើវិមានអីមួយ សម្រាប់តំណាងខ្មែរតំណាងក្នុងតំបន់យើង...ម៉ាលី ថៃ ក្រោយមកស្រាប់តែភ្លើងឆេះម្តងទៀត អស់មួយសារទៀតទៅ !

**ឡាច ប៊ុនរិទ្ធ:** ឡាចអាហ្គឹងស្នាដៃពួក ហ្គេងទៀតហើយ ពីព្រោះគេចាប់វាបានប្រពន្ធវាជាអ្នកឆ្លើយដាក់ ជាប់គុកដល់សព្វថ្ងៃនេះ...

**ម៉ាលី ថៃ (នៅមានតទៅលេខក្រោយ)**

តមកពីទំព័រទី ១៥
## មិនដល់មួយឆ្នាំផងបន្ទាប់ពីបើកដំណើរការ...

ជប៉ុន។ ដោយមានហាងសរុបចំនួន១៩០ រោងកុនអេក្រង់ប្រាំពីរមួយ កន្លែងជិះស្គីទឹកកក មួយស្ទូឌីយ៉ូទូរទស្សន៍មួយ និងកន្លែងលក់អាហារចម្រុះមួយកន្លែងនោះ ផ្សារទំនើបនេះ ផ្តល់នូវទំនិញដែលហាងផ្សេងៗទៀតក្នុងរាជធានីគ្មាន ហើយវាគឺជាជំហានដ៏សំខាន់មួយនៅក្នុងការពង្រីកសេដ្ឋកិច្ចនៅកម្ពុជា។

លោក ហ៊ុន សែន បានមានប្រសាសន៍នៅពេលនោះថា "ទីតាំងនេះគឺជាកន្លែងមួយដែលបង្ហាញពីសក្តានុពលសម្រាប់ការអភិវឌ្ឍនានានៅកម្ពុជា"។

ប៉ុន្តែ ទោះបីជាផ្សារទំនើបអ៊ីអនអះអាងថា មានមនុស្សប្រហែល១២លាននាក់បានមកផ្សាររបស់ខ្លួនចាប់តាំងពីពេលបើកទ្វារមកក៏ដោយ តែម្ចាស់ហាងមួយចំនួនដែលត្រូវបានសម្ភាសនៅក្នុងខែនេះបានបញ្ជាក់ប្រាប់ពី បញ្ហាមួយចំនួនដែលជះឥទ្ធិពលដល់ការលក់ និងដែលជាបញ្ហាដ៏គួរឱ្យព្រួយបារម្ភនោះ។

លោក ចាង ប៊ុនលាង ដៃគូគ្រប់គ្រងហាង Fox Wine Bistro បានលើកឡើងថា ទោះបីជាមានមនុស្សច្រើននាំគ្នាមកផ្សារទំនើបនេះជារៀងរាល់ថ្ងៃក៏ដោយ តែមានមនុស្សតែបន្តិចបន្តួចប៉ុណ្ណោះបានមកហាងរបស់ខ្លួន ដោយលោកបានពន្យល់ហេតុផលថា បរិស្ថានជុំវិញផ្សារទំនើបអ៊ីអន ក៏ជាផ្នែកមួយដែលជះឥទ្ធិពលដល់ការលក់ដែរ។

លោក ប៊ុនលាង បាននិយាយតាមទូរស័ព្ទថា "មានអតិថិជនជាច្រើនទៅ ឱ្យផ្សារទំនើបនេះឧ ប៉ុន្តែ តាមអ្វីដែលយើងសង្កេតឃើញគឺថា ពុំសូវមានមនុស្សទិញទំនិញឡើយ ជាពិសេសហាងដែលនៅខាងក្រៅអគារ ហេតុដូច្នេះទើបយើងសម្រេចបិទទ្វារ"។

លោកបាននិយាយបន្ថែមទៀតថា "តាមអ្វីដែលខ្ញុំនិងក្រុមការងារគិតគឺថា ប្រសិនបើយើងក្រឡេកមើលផ្សារទំនើបនៅក្នុងទីក្រុងផ្សេងៗ និងប្រទេសជិតខាង វាមិនមែនគ្រាន់តែជាផ្សារទំនើបនោះទេ។វាមានការិយាល័យនៅព័ទ្ធជុំវិញ ហេតុដូច្នេះមានមនុស្សមកហាងទាំងនោះ បន្ទាប់ពីធ្វើការងាររួច។ រីឯផ្សារទំនើបអ៊ីអនវិញ គឺគ្មានការិយាល័យណាមួយនៅព័ទ្ធជុំវិញឡើយ ហេតុដូច្នេះមនុស្សជាច្រើនបានមកផ្សារនេះ ហើយចូលទៅខាងក្នុងផ្សារដោយមិនបានចំណាយពេលវេលាសម្រាប់ហាងនៅខាងក្រៅអគារឡើយ"។

លោក Alex Matcheret ម្ចាស់ហាងនំប៉័ងបារាំងដែលទិញសិទ្ធិពីហាង Erikc Kayser ក៏បានលើកឡើងផងដែរថា ខណៈទីតាំងនៅខាងក្នុងផ្សារទំនើបអ៊ីអនមានមនុស្សយ៉ាងច្រើននោះ បរិវេណនៅខាងក្រៅពុំមានមនុស្សឡើយ ដោយលោកលើកឡើងពីមូលហេតុថា ផ្សារនេះធ្វើពុំទាន់ត្រូវតាមលក្ខណៈបច្ចេកទេស។

លោកបាននិយាយថា "យើងអាចឃើញស្រាប់ហើយថា នៅពេលអតិថិជនទៅផ្សារទំនើបអ៊ីអន ពួកគេចូលទៅក្នុងផ្សារតែម្តង ដោយមិនបានចាប់អារម្មណ៍ហាងនៅបរិវេណខាងក្រៅអគារឡើយ។ ប្រហែលជាពួកគេ ឱ្យផ្សារទំនើបអ៊ីអនឧ ត្រូវតែផ្លាស់ប្តូរអ្វីមួយដើម្បីទាក់ទាញអតិថិជនឱ្យចាប់អារម្មណ៍ផ្នែកខាងក្រៅឱ្យបានច្រើនហើយមើលទៅ"។

លោក Matcheret ដែលនិយាយថា លោកមានគម្រោងបើកហាង Eric Kayser មួយផ្សេងទៀតនៅអគារពាណិជ្ជកម្មវឌ្ឍនៈក្នុងខែកក្កដានោះបានគូសបញ្ជាក់ថា ការសាងសង់កន្លែងចតរថយន្តដែលមានកម្ពស់ជាច្រើនជាន់ជាប់បរិវេណនៅខាងក្រៅគឺជាបញ្ហាសម្រាប់ហាងដែលមានទីតាំងនៅទីនោះ។

លោកបាននិយាយថា "ឥឡូវនេះយើងដឹងហើយថា គេបានសម្រេចសាងសង់កន្លែងចតរថយន្ត ហើយវាបានធ្វើឱ្យបរិស្ថាននៅបរិវេណខាងក្រៅផ្លាស់ប្តូរទាំងស្រុង ហើយច្រកចូលវិញគឺវាមិនមានភាពងាយស្រួលសម្រាប់អតិថិជនទេ"។

រីឯលោក Jean-Pierre Muselli ម្ចាស់ហាង Original Steakhouse ដែលស្ថិតនៅបរិវេណខាងក្រៅដែរនោះបានលើកឡើងតាមរយៈអ៊ីម៉ែលមួយថា ហាងរបស់លោកទទួលរងផលប៉ះពាល់ទាំងស្រុងពីចំណតរថយន្តនេះ។ចាប់តាំងពីការសាងសង់បានចាប់ផ្តើមកាលពីខែធ្នូមកការលក់របស់លោកបានធ្លាក់ចុះគួរឱ្យកត់សម្គាល់។

លោកបានសរសេរថា "ការលក់របស់យើងធ្លាក់ចុះ៤០ភាគរយចាប់តាំងពីការងារសាងសង់ចាប់ផ្តើមមក។ នៅពេលអតិថិជនមិនអាចចតរថយន្តក្បែរហាងរបស់យើង ពួកគេបានប្តូរទៅហាងផ្សេងសម្រាប់អាហារថ្ងៃត្រង់ និងពេលល្ងាច។ ដំបូងឡើយយើងទទួលបានប្រាក់ចំណេញ ប៉ុន្តែ ឥឡូវនេះយើងបានខាតបង់ ជារៀងរាល់ខែ"។

តែទោះជាយ៉ាងណា លោក ជី សិលា អ្នកគ្រប់គ្រងទូទៅនៅក្រុមហ៊ុន CBM Corp ដែលភោជនីយដ្ឋាន Miam Miam របស់ខ្លួនមានទីតាំងស្ថិតនៅជាន់ទី៣ក្នុងផ្សារទំនើបអ៊ីអន ហើយបានបិទទ្វារកាលពីដើមខែនេះនោះបាននិយាយថា មិនមែនគ្រាន់តែហាងនៅបរិវេណខាងក្រៅនោះទេដែលជួបបញ្ហានោះ។

លោកបាននិយាយតាមទូរស័ព្ទថា "ភោជនីយដ្ឋាន Miam Miam បានបិទទ្វាររួចទៅហើយ ព្រោះយើងបានកត់សម្គាល់ថា អ្នកដែលមកផ្សារទំនើបនេះគ្មានលទ្ធភាពទិញម្ហូបអាហាររបស់យើងបានឡើយ ហើយខ្ញុំអាចនិយាយបានថា យើងជ្រើសរើសទីតាំងខុស"។

លោក សិលា បានលើកឡើងបន្ថែមថា អ្នកដែលចូលមកភោជនីយដ្ឋាន Miam Miam ត្រូវចំណាយចន្លោះពី១២ដុល្លារ ទៅ១៥ដុល្លារ ប៉ុន្តែ តាមជាក់ស្តែងមនុស្សភាគច្រើនដែលមកផ្សារទំនើបនេះមានលទ្ធភាពចំណាយត្រឹមតែ១០ដុល្លារ ឬក៏តិចជាងនេះ។

សិស្សវិទ្យាល័យម្នាក់ឈ្មោះ ជុត មីអ៊ីង ដែលមកផ្សារទំនើបអ៊ីអនកាលពីថ្ងៃអង្គារបានឱ្យដឹងថា តាមអ្វីដែលនាងដឹងគឺថា មនុស្សភាគច្រើនចូលចិត្តទៅកន្លែងលក់ម្ហូបអាហារជាន់ក្រោម។

នាងបាននិយាយថា "មានភោជនីយដ្ឋាន

តទៅទំព័រទី ២៩

Continued from page 15
## Amid Slow Sales, Some Aeon Tenants Leave...

Aeon's surroundings were to blame.

"There are many customers going [to the mall], but what we have observed and we have found out is that not many people are spending money on restaurants, particularly [on Terrace Avenue], so we decided to pull out," Mr. Bunleang said by telephone.

"From what I, and our team, thought, if you look at malls in other cities and neighboring countries, they're not just a mall. There are offices around, so there are people coming after work to hang out," he said. "Aeon Mall, it's not connected to any offices, so most of the people are actually driving to the mall and hanging out on top of the mall and not on the avenue."

Alex Matcheret, the owner of Cambodia's Eric Kayser franchise, also said that while certain areas of Aeon Mall enjoyed heavy foot traffic, Terrace Avenue was noticeably emptier, attributing the problem to the flow of patrons through the shopping center.

"You can see when the customers come to Aeon they're going directly inside the mall, they're not passing by Terrace Avenue," he said. "Maybe they [Aeon] have to change something to attract more people."

Mr. Matcheret—who said he planned to open another Eric Kayser restaurant in the Vattanac Capital Tower in July—noted that the construction of a multistory parking garage adjacent to Terrace Avenue was proving troublesome for restaurants located there.

"[Y]ou know now they decided to build the parking and it's changing completely the layout of Terrace Avenue, and the access is not easy for the customers," he said.

Jean-Pierre Muselli, the owner of The Original Steakhouse on Terrace Avenue, said in an email that his restaurant had felt the full impact of the parking garage. Since construction began in December, he said, sales had dropped significantly.

"Our business drop down by 40% since the beginning of the works," he wrote. "As the customers cannot park next to our shop they prefer to go to another place for lunch or dinner…. We come from a profitable business to currently lose some money every month.")

Issues with restaurant sales were not limited to Terrace Avenue, however, said Chy Sila, general manager of CBM Corp., whose Miam Miam restaurant, which had been located on the third floor of the mall, closed earlier this month.

"Miam Miam has been closed already because we have noticed and seen that people who visit the mall could not afford our products and I can say that we chose the wrong location," Mr. Sila said by telephone.

Mr. Sila said patrons of Miam Miam—which bills itself as "The French Cafe with a Japanese Twist!"—were expected to be able to spend between $12 and $15, but that in reality, most people who came to the mall could spend just $10 or less.

Chut Mey Ing, a local high school student shopping at Aeon on Tuesday, said that in her experience, most visitors preferred the food options at the mall's supermarket on the ground floor.

"There are a lot of different types of restaurants from different countries like Italy and Japan in the mall, but I have noticed that mostly people like to come eat [at the supermarket] downstairs because it has food that Cambodians like and the prices are reasonable," she said.

In an email this week, Yajima Makoto, managing director of Aeon Mall Cambodia, said that while the mall was disappointed that tenants were leaving, closures are normal at shopping centers.

"Of course it is…unfortunate for us and tenants to close their stores," Mr. Makoto wrote. "But for the shopping mall operation, it is our customer's demands which supports our business so it is normal for the rearrangement for inviting new brands and tenants."

Mr. Makoto did not respond to additional requests for comment on tenants' complaints about construction and location.

Luu Meng, president of the Cambodia Hotel Association, said that future commercial development in the country partly hinged on Aeon's success.

"It is a showcase Cambodia can use," said Mr. Meng, who is also a shareholder in the Khmer World Food Court on the mall's third floor and director of the Thalias group, which owns Khema, a restaurant on Terrace Avenue.

"If Aeon Mall doesn't work, we have a lot of investment [that is] going…to wait, but if this shopping mall gets better, I think a lot of new investment [is] on the way."

# រមណីដ្ឋានទឹកធ្លាក់

# ល្បាក់ខោន (ឬ សុភមិត្រ)







នៅក្នុងរដូវភ្លៀងនៅពេលដែលទឹកទន្លេចាប់ផ្តើមឡើងពេញប្រៀបមាត់ច្រាំងដោយទំហំទឹកធំ និង ល្បឿនកាន់តែខ្លាំងនោះ បានបង្កើតឱ្យមានទស្សនីយភាពកាន់តែស្រស់ស្អាត គួរជាទីគយគន់ជាមួយផ្សែងអ័ព្ទដែលបានផុសចេញពីទឹកដែលកំពុងធ្លាក់។ ចំណែកឯនៅក្នុងរដូវប្រាំងវិញ ទឹកក៏ចាប់ផ្តើមចុះស្រក បាននាំឱ្យទីនេះលេចចេញនូវទេសភាពល្អត្រកាល ប្រែក្លាយជាវាល ដែលរំលេច ដោយថ្មពណ៌ក្រហម ខ្មៅ និងស ។ តែ

តទៅទំព័រទី ២៥






# សហគមន៍ខ្មែរកម្ពុជាក្រោម

THE KHMER KAMPUCHEA KROM COMMUNITY
LA COMMUNAUTÉ DU KHMER KAMPUCHEA KROM

លេខ:..................ស.ខ.ក.ក.

## លិខិតអំពាវនាវ

សហគមន៍ខ្មែរកម្ពុជាក្រោម និងសម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យ សូមព្រះអនុញ្ញាត និងអនុញ្ញាត ប្រគេន និងជម្រាបជូន ព្រះករុណាគ្រប់ព្រះអង្គ បងប្អូនជនរួមជាតិ ព្រះមេត្តា និងមេត្តាជ្រាបថា ការស្រាវជ្រាវយកឯកសារទាក់ទងនឹងទឹកដីខ្មែរកម្ពុជាក្រោមនៅ Aix-En-Provence ប្រទេសបារាំងបានបញ្ចប់ដោយជោគជ័យ។

ការស្រាវជ្រាវរបស់យើងបានរកឃើញឯកសារសំខាន់ៗ ដែលទាក់ទងនឹងការកាត់ផ្ទេរទឹកដីខ្មែរកម្ពុជាក្រោមរបស់អាណានិគមបារាំង ឱ្យអាណានិគមយួនត្រួតត្រាបន្ត មានដូចជា សន្ធិសញ្ញាបារាំង-យួន, កិច្ចព្រមព្រៀងបារាំង-យួន, កំណត់ហេតុប្រជុំសភាបារាំងក្នុងការផ្ទេរទឹកដីខ្មែរឲ្យយួន, ច្បាប់កាត់ផ្ទេរទឹកដីខ្មែរឲ្យយួន, ការទាមទារទឹកដីខ្មែរកម្ពុជាក្រោមមកវិញរបស់អតីតព្រះមហាក្សត្រខ្មែរ, ការប្រឆាំងជំទាស់ការតវ៉ារបស់រាជរដ្ឋាភិបាលខ្មែរ និងអតីតព្រះមហាក្សត្រខ្មែរជាដើម។ ឯកសារសំខាន់ៗ ដែលយើងរកឃើញមានប្រមាណជាង ៥.០០០ទំព័រ ហើយតម្លៃដែលត្រូវថតចម្លងចេញពីបណ្ណសារដ្ឋានជាតិបារាំង Aix-En-Provence នោះ ចំនួន ១៦.០០០€ (មួយម៉ឺនប្រាំមួយពាន់អឺរ៉ូ) ជិតពីរម៉ឺនដុល្លារអាមេរិក។

នេះជាជោគជ័យជាប្រវត្តិសាស្ត្រដ៏ធំធេងមិនធ្លាប់មាន ដែលផ្តើមចេញពីការខិតខំតស៊ូរបស់ព្រះករុណាគ្រប់ព្រះអង្គ បងប្អូនជនរួមជាតិ និងយុវជនខ្មែរនៅគ្រប់ទិសទី ដែលបានជួយឧបត្ថម្ភគាំទ្រនិងចូលរួមធ្វើមហាបាតុកម្មយ៉ាងសកម្មកន្លងមក។

ដើម្បីថតចម្លងយកឯកសារដ៏មានសារសំខាន់នេះ មកប្រើប្រាស់ជាប្រយោជន៍ដល់ជាតិខ្មែរយើង សហគមន៍ខ្មែរកម្ពុជាក្រោម និងសម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យ សូមលំឱនកាយគោរពអំពាវនាវដល់ព្រះករុណាព្រះតេជគុណម្ចាស់គ្រប់ព្រះអង្គ បងប្អូនជនរួមជាតិទាំងអស់ សូមព្រះមេត្តា និងមេត្តាជួយឧបត្ថម្ភជាថវិកាជាបន្ទាន់ទៅតាមសទ្ធាជ្រះថ្លា ដើម្បីយើងខ្ញុំមានលទ្ធភាពបង់ថ្លៃថតចម្លងចំនួន ១៦.០០០€ ព្រោះគេនឹងថតចម្លងឲ្យយើងនៅពីរសប្តាហ៍ខាងមុខនេះ។ ចំពោះការបកប្រែជាភាសាខ្មែរ ជាភាសាអង់គ្លេស និងការបោះពុម្ព យើងខ្ញុំនឹងជម្រាបជូនខាងក្រោយ។

សហគមន៍ខ្មែរកម្ពុជាក្រោម និងសម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យ មានសេចក្តីសង្ឃឹមយ៉ាងមុតមាំទៅលើស្មារតីស្នេហាជាតិរបស់ព្រះករុណាគ្រប់ព្រះអង្គ បងប្អូនជនរួមជាតិ ក្នុងការឆ្លើយតបតាមការអំពាវនាវរបស់យើងខ្ញុំទាន់ពេលវេលា ដើម្បីជំរុញបេសកកម្មជាតិឲ្យដល់គោលដៅជាក់ជាមិនខាន។

វិភាគទានរបស់ព្រះករុណាព្រះតេជគុណម្ចាស់គ្រប់ព្រះអង្គ បងប្អូនជនរួមជាតិ ពិតជាបានចូលរួមចំណែកកសាងប្រវត្តិសាស្ត្រ និងបម្រើផលប្រយោជន៍ជាតិខ្មែរដ៏ពិតប្រាកដ។

សូមប្រគេនពរនិងជូនពរទៅព្រះទាំង ៥ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៥
ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម
ប្រធានបណ្តោះអាសន្នសម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យ

ថាច់ សេដ្ឋា



**បញ្ជីឈ្មោះ, ចំនួនលុយរបស់លោកអ្នក, យើងខ្ញុំនឹងផ្ញើរជូនដល់ទីស្នាក់ការមានអាសយដ្ឋានដូចខាងក្រោម៖**

ទីស្នាក់ការ: ផ្ទះលេខ ៧២ ផ្លូវលេខ ៤២៦A ភូមិពោធិឃ្លាំង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥) ០១២ ៥០៨ ៨៨២ / ៩៣ ៤៧ ៤៧ ០៦
E-mail: thachsetha13@gmail.com, Website: khmerkromngo.org



## តមកពីទំព័រទី ០៤ របាយការណ៍អំពីក្លឹបសារព័ត៌មាន...

ប្រធានសមាគមអាជីវករ Cupples Square Merchants Association មានប្រសាសន៍ ថា គាត់ "យល់ស្របក្នុងការជំទាស់" ទៅនឹងបូជនីយដ្ឋាន ដែលជាគម្រោងរបស់អង្គការក្រុងខ្មែរ (Cambodia Town)។ គាត់មិនជំទាស់ទេ បើសហគមន៍ខ្មែរ បានមូលមតិគ្នា គាំទ្រឱ្យសាងសង់បូជនីយស្ថាននេះ។ ប៉ុន្តែគាត់ខ្លាចក្រែងតែគម្រោងនេះធ្វើឡើងដោយគ្មានការយល់ស្របជារួមពីប្រជាពលរដ្ឋទូទៅនៅក្រុងឡូវែល។ គាត់ឆ្ងល់ហេតុអ្វីបាន ជាចាំបាច់យកលុយពីរដ្ឋាភិបាលខ្មែរបច្ចុប្បន្ន មកឡូកឡំក្នុងការសាងសង់បូជនីយដ្ឋានខ្មែរនៅក្រុងឡូវែលនេះ។ តើការធ្វើដូច្នេះវាសមដែរឬទេ។


លោក ស៊ីតនី លាង

លោក ស៊ីតនី លាង ដែលជាសមាជិកមួយរូបក្នុងគណៈកម្មាធិការគម្រោងសង់បូជនីយស្ថានខ្មែរ ដែលផ្តួចផ្តើមដោយលោកអភិបាលក្រុងឡូវែល បានមានប្រសាសន៍ថា សព្វថ្ងៃនេះសហ គមន៍ខ្មែរក្នុងក្រុងឡូវែល មានភាពប្រេះឆាគ្នាយ៉ាងខ្លាំង ដោយសារតែបញ្ហានយោបាយនៅកម្ពុជា។

គាត់ថា យកលុយរដ្ឋាភិបាលខ្មែរគួរទុកលុយសម្រាប់ជួយចេញថ្លៃសង់បូជនីយស្ថាននៅក្នុងក្រុងឡូវែលនេះ ដើម្បីយកទៅជួយពលរដ្ឋខ្មែរក្រីក្រនៅស្រុកខ្មែរវិញ ទើបប្រសើរជាង។ គាត់យល់ថា បូជនីយស្ថានមួយដែលមានអត្ថន័យ និងតម្លៃទៅបាន គឺទាល់តែជារបស់ដែលអ្នកក្រុងឡូវែលខ្លួនឯង ជាអ្នកសាហការគ្នាចេញប្រាក់ដើម្បីសាងសង់។ គាត់មានប្រសាសន៍បន្តថា ទោះជាត្រូវសង់បូជនីយស្ថានអ្វីមួយនៅទីក្រុងឡូវែលនេះគាត់ចង់ឱ្យសង់អ្វីដែលជានិមិត្តរូបនៃឯកភាពជាតិខ្មែរ។ គាត់មានសេចក្តីត្រេកអរដែលនឹងមានគម្រោងសាងសង់បូជនីយស្ថានមួយដាច់ដោយឡែកទៀត នៅក្នុងបរិវេណនៃសាលាក្រុងឡូវែល។ ថ្មីៗនេះ សហគមន៍អាមេរិកបានសាងសង់បូជនីយស្ថានមួយ ដែលចំណាយទឹកប្រាក់ ៦៥,000 ដុល្លា។ គាត់ថា បូជនីយស្ថានខ្មែរដែលនឹងត្រូវសាងសង់ ក៏នឹងត្រូវចំណាយប្រាក់មិនតិចជាងនេះនោះដែរ។

លោក ខែវិន ខហ្លីន នាយករងនៃមន្ទីរផែនការ និងអភិវឌ្ឍន៍ក្រុង មានប្រសាសន៍ថា សាលាក្រុងឡូវែលមើលឃើញនូវសារសំខាន់នៃនិមិត្តរូបនៃកម្លាំងសាមគ្គីរបស់សហគមន៍ខ្មែរ។ នៅក្នុងគណៈកម្មាធិការ ដែលជ្រើសរើសរូបបូជនីយស្ថានដែលត្រូវសាងសង់នៅក្នុងបរិវេណសាលាក្រុងឡូវែលនេះ មានសមាសភាពមកពីគ្រប់មជ្ឈដ្ឋានរួមមានវិចិត្រករ និង តំណាងអង្គការផ្សេងៗ នៅក្នុងសហគមន៍ខ្មែរក្រុងឡូវែល។ លោកសង្ឃឹមថា ការសាងសង់បូជនីយស្ថានខ្មែរនៅក្នុងបរិវេណសាលាក្រុងឡូវែលនេះ នឹងចូលរួមយ៉ាងសំខាន់ក្នុងគម្រោងរបស់សាលាក្រុងឡូវែល ដើម្បីបង្កើត "សួនបូជនីយស្ថាន"នៅក្នុងទីធ្លាសាលាក្រុងឡូវែល។ សួននេះនឹងក្លាយជាទីសម្រាប់មនុស្សទូទៅមកលេងកំសាន្ត និងជាទីសម្រាប់សាងសង់បូជនីយស្ថាននៅចំកណ្តាលបេះដូងនៃក្រុងឡូវែល ដ៏មមាញឹកនៃយើង៕


David Parker


Daniel Mc faden

សារព័ត៌មានខ្មែរផុស- ស.រ.អា






CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។
យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

ការធានារ៉ាប់រងគ្រួសារ
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បៈ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វើកខម (Worker's Compensation)
- បុនដស៍ (Bonds)
- អ្នកមើលថែម្យាន និងការរ៉ាស់ម្យាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY INSURANCE AGENCY
77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

ខូម័រ សិប្បកម្មឆ្លាក់សំណាកក្រានីត
COLMER MONUMENT WORKS

Memorials of Distinction
អាសយដ្ឋាន:1025 Lawrence Street Lowell, MA 01852-4898
(978) 452-7821



- Granite Memorials — ផ្នូររាងបញ្ឈរធ្វើពីថ្មក្រានីត
- Granite & Bronze Markers — ផ្នូរផ្តេកមានឆ្លាក់សំរិទ្ធលើថ្មក្រានីត
- Cemetery Lettering in Khmer — មានឆ្លាក់អក្សរខ្មែរលើថ្មនៃផ្នូរ

COLMER Monument Works
ភាពថ្លៃថ្នូរ កិត្តិយស និងការគោរពជូនលោកអ្នក
Honor. Dignity. Respect for All

តមកពីទំព័រទី ១៨ **រមណីដ្ឋានទឹកធ្លាក់ល្បាក់ខោន...**

ភ្ញៀវទេសចរដែលបានទៅលេងនៅទីនោះ ក៏ត្រូវប្រយ័ត្ន នឹងដុំថ្មស្រួចៗរដិបរដុបដែលនៅទីនោះផងដែរ ។

ចំណែកលោក កាំ ពួយបាននិយាយថា ខាងពីមុនទីនេះពុំសូវមានភ្ញៀវទេសចរមកទស្សនាទេ ពីព្រោះការធ្វើដំណើរតាមទូកបានជួបការលំបាកដោយត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ ដោយសារបុក នឹងរបាំងថ្មធំៗដែលនៅក្នុងទន្លេ ។

ដូចគ្នានេះដែរ អ្នកស្រុករស់នៅតំបន់នេះបាននិយាយថា ភ្ញៀវទេសចរ មិនហ៊ានជិះទូកមកទីនេះទេ ព្រោះខ្លាចបុកនឹងរបាំងថ្ម និងខ្លាចទឹកដែលមានល្បឿនខ្លាំងនៅទីនេះកួចយកទៅ ហើយមាន តែអ្នកដែលរស់នៅទីនេះ ដែលដឹងពីល្បឿនទឹក និងស្ថានភាពផ្លូវទឹកច្បាស់ ដែលអាចធ្វើដំណើរមកទីនេះបាន ។

នៅពេលថ្មីៗនេះ ក៏មានក្រុមទេសចរបានចាប់ផ្តើមធ្វើដំណើរមកកំសាន្តនៅរមណីដ្ឋានទឹកធ្លាក់ ល្បាក់ខោននេះដែរ ហើយពួកគេមួយចំនួនជាភ្ញៀវទេសចរ ហើយបានស្លៀកសំលៀកបំពាក់ការពារសុវត្ថិភាពនៅពេលដែលពួកគេធ្វើដំណើរតាមទូកមកទស្សនានៅទីនោះ ។

លោក កាំ ពួយ បាននិយាយបន្តទៀតថា "ទោះបីជាយ៉ាងណាក៏ដោយ ពួកគេហាក់ដូចជាពេញចិត្ត នឹងការធ្វើដំណើរថ្មើជើងនៅជុំវិញបរិវេណ ទឹកធ្លាក់ ជាងការធ្វើដំណើរដោយទូក ។ ពីព្រោះថា នៅរដូវប្រាំង ទឹកចាប់ផ្តើមស្រក ហើយកំលាំងទឹកខ្សោយ ។ ចំណែកនៅរដូវវស្សាវិញ ទឹកមានទំហំធំ ទឹកកួចមានល្បឿនខ្លាំង និងហូរលឿន ដែលនាំឱ្យទូកពិបាកឆ្លងកាត់ ។ ហើយគាត់បន្តទៀតថា "នៅរដូវណាក៏ដោយ ក៏ធ្លាក់នៅទីនេះប្រកបដោយសភាពគ្រោះថ្នាក់ជានិច្ច" ។

អ៊ុំកាំ ពួយបានរស់នៅក្នុងភូមិ អន្លង់ស្វាយ ឃុំព្រះរុំកិល ស្រុកថាឡាបូរីវ៉ាត់ ខេត្តស្ទឹងត្រែង ។ គាត់ បាននិយាយថា ទីនេះសម្បូរត្រីខ្លាំងណាស់ នៅពេលទឹកធ្លាក់ ។ ទឹកធ្លាក់ល្បាក់ខោន ឬទឹកធ្លាក់សុភមិត្រ គឺជាតំបន់មួយដែលទឹកទន្លេមេគង្គហូរឆ្លងកាត់ ហើយស្ថិត នៅក្នុងឃុំ ព្រះរំកិល ស្រុកថាឡាបូរីវ៉ាត់ ខេត្តស្ទឹងត្រែង និងស្ថិតក្នុងភូមិ កំពង់ស្រឡៅ ស្រុកឆែប ខេត្តព្រះវិហារ នៃព្រះរាជាណាចក្រកម្ពុជា ៕









តមកពីទំព័រទី ១៤ សកម្មជនដីធ្លីត្រូវបានដោះលែង បន្ទាប់ពី...

អស់រយៈពេលជាច្រើនខែ ។

ពេលចេញពីពន្ធនាគារព្រៃសក្នុងរាជធានីភ្នំពេញប្រហែលម៉ោង៣និង៣០នាទីរសៀលថ្ងៃសៅរ៍ សកម្មជនសិទ្ធិដីធ្លីទាំងនេះដែលរួមមានដូចជា អ្នកស្រី ទេព វន្នី អ្នកស្រី ង៉ែត យុន អ្នកស្រី សុង ស្រីលាភ អ្នកស្រី គង់ ចន្ថា អ្នកស្រី ផាន់ ឈុនរ៉េត អ្នកស្រី បូវ ឆវី អ្នកស្រី ណុង ស្រេង អ្នកស្រី ហេង ពេជ្រ អ្នកស្រី អ៊ឹម ស្រីទូច និងអ្នកស្រី ភួង សុភាព ត្រូវបានទទួលស្វាគមន៍ដោយសាច់ញាតិ សមាជិកសហគមន៍ និងមន្ត្រីគណបក្សសង្គ្រោះជាតិប្រហែល១០០នាក់ ។

អ្នកស្រី ទេព វន្នី បាននិយាយកាលពីថ្ងៃសៅរ៍ថា "យើងទាំង១០នាក់សប្បាយចិត្តខ្លាំងណាស់ដែលបានមកជួបជុំគ្រួសារឡើងវិញ ជាពិសេសកូនៗរបស់យើង សហគមន៍ និងអង្គការ ។ យើងជាមនុស្សគ្មានទោសពៃអ្វីឡើយ ហើយយើងទទួលរងការធ្វើបាបដ៏អយុត្តិធម៌ពីសំណាក់តុលាការមិនឯករាជ្យនៅកម្ពុជា ដែលចាប់ខ្លួនយើងដាក់គុកអស់រយៈពេល៥ខែ" ។

ពេលនិយាយតាមទូរស័ព្ទកាលពីម្សិលមិញ អ្នកស្រី ទេព វន្នី បាននិយាយថា ការដោះលែងសកម្មជនសិទ្ធិធ្លីក្រោយពេលគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិបានបញ្ចប់ការចរចាស្តីពីកំណែទម្រង់ការបោះឆ្នោតអស់រយៈពេល៨ខែរបស់ខ្លួនកាលពីថ្ងៃព្រហស្បតិ៍ វាបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា ការចាប់ខ្លួននេះគឺជារឿងនយោបាយ ។

អ្នកស្រី ទេព វន្នី បាននិយាយបន្តថា "រដ្ឋាភិបាលកម្ពុជាខ្សោយ ហើយថោកទាប ព្រោះ ថាឱ្យលោក ហ៊ុន សែន គ្មានសមត្ថភាពប្រកួតប្រជែងជាមួយដៃគូរបស់ខ្លួនតាមផ្លូវច្បាប់ ហេតុដូច្នេះគាត់ប្រើល្បិចដ៏ថោកទាបមកធ្វើបាបពលរដ្ឋស្លូតត្រង់។ យើងត្រូវបានគេប្រើប្រាស់ជា ឧបករណ៍នយោបាយ ហើយត្រូវបានចាប់ដាក់គុកដោយអយុត្តិធម៌" ។

ប៉ុន្តែអ្នកស្រី ទេព វន្នី បានលើកឡើងថា អ្នកស្រីសង្ឃឹមថា គណបក្សសង្គ្រោះជាតិ មិនបានដកការទាមទារណាមួយរបស់ខ្លួនចេញពីការចរចាស្តីពីកំណែទម្រង់ការបោះឆ្នោតតាមអ្វីដែលគណបក្សប្រជាជនកម្ពុជាបានទាមទារ ដើម្បីជាថ្នូរឱ្យមានការដោះលែងអ្នកស្រី និងសកម្មជនផ្សេងទៀតពីពន្ធនាគារនោះឡើយ ។

អ្នកស្រីបាននិយាយថា "ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឱ្យថ្មី ដែលកំពុងត្រូវបានបង្កើតឡើងគឺជាគណៈកម្មាធិការដែលអព្យាក្រឹត ឯករាជ្យ និងមិនពុករលួយនោះ អ៊ីចឹងការជាប់គុករបស់យើងគឺមានតម្លៃ ហើយយើងសប្បាយចិត្ត" ។

អ្នកស្រី សុង ស្រីលាភ សកម្មជនសិទ្ធិដីធ្លីដែលត្រូវបានដោះលែងម្នាក់ទៀត បានលើកឡើងថា គ្មានអ្វីត្រូវសង្ស័យទេ ការចាប់ខ្លួនហ្នឹងគឺពិតជារឿងនយោបាយ ។

អ្នកស្រីបាននិយាយថា " យើងគឺជាចំណាប់ខ្មាំងនយោបាយសម្រាប់ការចរចាពាក់ព័ន្ធ ទៅនឹងគ.ជ.ប.។ បន្ទាប់ពី គ.ជ.ប. ត្រូវបានបង្កើត យើងក៏ត្រូវបានដោះលែងដែរ" ។

លោក សុខ ទូច អ្នកវិភាគនយោបាយឯករាជបានលើកឡើងថា សកម្មជនទាំង១០នាក់នេះបានប្រព្រឹត្តខុសនឹងច្បាប់តែបន្តិចបន្តួចប៉ុណ្ណោះ ចំពេលកិច្ចពិភាក្សាស្តីពីកំណែទម្រង់ការបោះឆ្នោតកំពុងជាប់គាំង ប៉ុន្តែគេបែរជាចាប់កំហុសនេះដើម្បីធ្វើជាលេសដាក់សម្ពាធមិនឱ្យគណបក្សសង្គ្រោះជាតិធ្វើការទាមទារច្រើនអំឡុងការចរចាទៅវិញ ។

លោកបានមានប្រសាសន៍ថា "នៅពេលអ្នកនយោបាយព្យាយាមប្រើអំណាចពីកន្លែងដែលខ្លួនអាចធ្វើបាន ហើយអ្នកម្ខាងទៀតប្រឈមមុខជាមួយពួកគេដោយប្រើប្រព័ន្ធតុលាការ ហើយប្រសិនបើសកម្មជនណាមួយរំលោភបំពានច្បាប់ឱ្យរដ្ឋាភិបាលខុ នឹងអនុវត្តច្បាប់ដើម្បីបង្ហាញថាខ្លួនមានសមត្ថភាពក្នុងការទប់ទល់ជាមួយដៃគូប្រជែងរបស់ខ្លួន" ។

លោក ឈឹម ផលវរុណ អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា បានលើកឡើងថា លោក ហ៊ុន សែន បានស្នើឱ្យមានការលើកលែងទោសសកម្មជនទាំង១០នាក់នេះ ប៉ុន្តែថា សំណើនេះមិនមែនកើតចេញពីកិច្ចព្រមព្រៀងនយោបាយទេ គឺដោយសារតែស្ត្រីទាំងនេះមានការកែប្រែអត្តចរិតបានល្អជាងមុននៅក្នុងពន្ធនាគារ ។

លោកបានមានប្រសាសន៍ថា "ហេតុដូច្នេះតុលាការអាចស្នើឱ្យក្រសួងយុត្តិធម៌ពិនិត្យអំពីបញ្ហានេះ ហើយបន្ទាប់មក ឱ្យក្រសួងរាយការណ៍ជូនលោកនាយករដ្ឋមន្ត្រី ហេតុដូច្នេះ លោក-នាយករដ្ឋមន្ត្រីអាចប្រើសិទ្ធិរបស់លោកដើម្បីទូលសុំព្រះមហាក្សត្រព្រះរាជទានលើកលែងទោសអ្នកទាំងនោះ ដែលតុលាការមើលឃើញថា មានការកែប្រែអត្តចរិតបានល្អជាងមុន" ។

លោក ឈឹម ផលវរុណ បានមានប្រសាសន៍បន្ថែមទៀតថា "ការដោះលែងអ្នកទោសទាំងនេះគ្មានពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងនយោបាយរវាងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងលោក សម រង្ស៊ី ទេ ព្រោះការដោះលែងអ្នកទោស គឺជាអំណាចរបស់តុលាការ" ។

ការបើកសវនាការជុំវិញសំណើសុំនៅក្រៅឃុំដាច់ដោយឡែកមួយទៀតសម្រាប់មន្ត្រីមកពីគណបក្សសង្គ្រោះជាតិចំនួនប្រាំរូប និងអតីតព្រះសង្ឃដែលមានទំនាក់ទំនងជាមួយគណបក្សប្រឆាំងចំនួនបីរូបផ្សេងទៀត ដែលឥឡូវសុទ្ធតែកំពុងជាប់ពន្ធនាគារគឺគ្រោងធ្វើឡើងនៅថ្ងៃនេះ ។ លោក ជួង ជូងី មេធាវីតំណាងឱ្យគណបក្សសង្គ្រោះជាតិដែលទទួលបន្ទុកក្នុងសំណុំរឿងនេះបានលើកឡើងកាលពីថ្ងៃសុក្រថា ការបើកសវនា ការនេះនឹងអាច នាំទៅរកការដោះលែងអ្នកទាំងប្រាំបីរូបនេះ ៕ ស៊ុយឈាង


ហ្វេយ៍មីកខេប ផ្ទះសម្រាប់ពិធីបុណ្យសព

Fay McCabe Funeral Home

105 Moore Street. Lowell, MA 01852

978-459-9222



បម្រើសហគមន៍ខ្មែរដោយការយកចិត្តទុកដាក់ កិត្តិយស
និងការគោរពជាង៣០ឆ្នាំមកហើយ

- Serving All Faiths — បម្រើសេវាកម្មគ្រប់ជំនឿ
- Traditional Funerals — កម្មវិធីបុណ្យសពជាលក្ខណៈប្រពៃណី
- Cremation Services — មានផ្តល់សេវាបូជាសព
- Pre Arranged Funerals — រៀបចំរោងមុនកម្មវិធីបុណ្យសព

Locates 1 mile from Glory Buddhist Temple,
between Gorham St. & Lawrence St.

ទីកន្លែងនៅចំងាយ១ម៉ាយពីវត្តពន្លឺពុទ្ធចក្ក
ចន្លោះផ្លូវ Gorham St. & Lawrence St.

លោកអ្នកនឹងក្រុមគ្រួសារទទួលបាននូវការយកចិត្តទុកដាក់
និងការបម្រើល្អប្រពៃពីទីនេះ ។

www.faymccabe.com

មានបុគ្គលិកនិយាយភាសាខ្មែរ

# បន្តដំណើរយុត្តិធម៌ដោយសិល្ប
## "Pursuing Justice Through Art".

By RobertChea

នៅឡូវែល ការតាំងពិព័ណ៌ផ្ទាំងគំនូរមួយដែលមានឈ្មោះថាឱ៉បន្តដំណើរយុត្តិធម៌ដោយសិល្បឱបានត្រូវរៀបចំឡើងជូនសាធារណជនកាលពីថ្ងៃទី២១មិនា២០១៥ នៅអាគារវិស្ល័រហារ ។ ឆ្នាំនេះគេសហការណ៍ជាមួយសិល្បករដើម្បីឧទ្ទិសដល់ចងចាំនៃរបបវាលពិឃាដនានា ។ អ្នកស្រីនាយកសារ៉ា បូកស្យាន បានថ្លែងថា «**សិល្បនេះជាជាការអប់រំផង ជាវត្ថុបំណងឱ្យសាធារណជនមានការប្រុងប្រយ័ត្នចំពោះអតីតកាល ដើម្បីទៅប្តូរអនាគត**» ។ រ៉ប៊ឺតបានទៅមើលការតាំងពិពត៌នោះ ហើយបានសរសេរការ-ចាប់អារម្មណ៍ ជាភាសាអង់គ្លេស ដូចតទៅ ។

